CEN
CAMBODIA EXPRESS NEWS

# ស្នេហាចុកឈាម
# របស់កម្លោះវែរទែរ

វិភាគប្រលោម លោក “Lessouf frances du Jeune Werther”

របស់ **“ក្លឺត”** (Goethe)

ដោយ **ទ៉ាន់ឌី ភារុន**

ការផ្សាយរបស់អ្នកនិពន្ធ

ព.ស.២៥១៨ គ.ស.១៩៧៤

# សេចក្តីផ្តើម

ប្រលោមលោកឈ្មោះ Les souffrannces  du Jeune Werther  របស់កវីអាល្លឺម៉ង់ "ស្ហូហាន់ វ៉ុលក្ហង់ក្អឺ" (Johann Wolfgang Gœthe ) នេះជាស្នាដៃអក្សរសិល្ប៍មួយមានតម្លៃសាកល ដែលអ្នកអក្សរសិល្ប៍ក្នុងលោកទទួលស្គាល់ ហើយដែលគេបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាមធ្យមសិក្សា ក្នុងការសិក្សាចលនាអក្សរសិល្ប៍អណ្តែតអណ្តូងនិយម ។ មួយចំណែកទៀតឥទ្ធិ ពលរបស់កវី ក្ហឺត នេះបានជះទៅលើអក្សរសិល្ប៍អណ្តែតអណ្តូងនិយមបារាំង យ៉ាងខ្លាំងក្លាណាស់ដែរ គឺទន្ទឹម គ្នានឹងឥទ្ធិពលរបស់កវីអង់គ្លេស "វ៉ាល់ទើរ ស្កុត្ត " ( Walter Scott ) ។

តទៅនេះ គឺការធ្វើវិភាគមនោសញ្ចេតនារបស់កម្លោះ"វ៉ែរទែរ" ដែលមានបេះដូងយ៉ាងទន់ភ្លន់ ហើយដ៏កាចសាហាវបំផុតក្នុងសេចក្តីស្នេហាដ៏ឥតព្រំដែនរបស់ខ្លួន ។ ឥតព្រំដែន ? តើស្នេហាអ្វីដែលមានលក្ខណៈបរិសុទ្ធហើយដែលមានព្រំដែននោះ ? តើអ្វីទៅជាព្រំដែន ? — ចរិយាធមិ ?- ចំពោះកម្លោះ " វ៉ែរទែរ "ចរិយាធមិពុំអាចជាព្រំដែនរបស់កម្លាំង " ចិត្ត " បានឡើយ ។ បើបាន ក៏ពុំមែនពិតដែរ ពីព្រោះនៅក្នុងលោកយើងនេះ តណ្ហា, ជាពិសេស តណ្ហានៃ សេចក្តីស្នេហា ជាសកម្មភាពនៃជីវិតមនុស្សលោកទាំងមូល ទោះបីសកម្មភាព នោះមានឈ្មោះថាជាសកម្មភាពនយោបាយ ឬ ជំនឿសាសនីក៏ដោយ ។ ចរិ យាធមិគ្រាន់តែជាការរៀបចំសណ្តាប់ធ្នាប់ សំរាប់ប្រើសន្តិសុខរបស់សេរីភាពអត្តទត្ថរបស់បុគ្គលម្នាក់ៗតែប៉ុណ្ណោះ (La morale, c’est l’ensemble deconventions socials qui garantissent la liberate égoiste de chaque individu) ។ ប៉ុន្តែបេះដូងរបស់កម្លោះ វ៉ែរទែរ ភ្លេចទាំងស្រុងនូវព្រំ ដែន សិប្បនិមិត្តនេះ ។

កម្លោះ វ៉ែរទែរ លួចស្រឡាញ់ប្រពន្ធគេ ហើយបណ្តែតខ្លួនទៅ តាម ខ្យល់ព្យុះដ៏ធំធេងមួយ ដែលបាននាំខ្លួនគេទៅរកវាលវដ្តសង្សារឥតកោះត្រើយនៃតណ្ហានិងមនោសញ្ចេតនា ។ គេភ្លេចអស់នូវច្បាប់ទំលាប់របស់សង្គមមនុស្ស ដែលគ្មានលទ្ធភាពនឹងគ្រប់ដណ្តប់មនោសញ្ចេតនាដ៏ធំធេង ហើយល្ងីងល្ងើយរបស់គេ ។ ដើម្បីសេចក្តីស្នេហាដ៏បរិសុទ្ធ ហើយដែលផ្ទុយនឹងសីលធមិមួយដ៏ខ្លាំងក្លា គេសុខចិត្តធ្វើដំណើរទៅរកបរលោក ។ ចិត្តពាសមេឃឥតព្រំដែននេះ ហើយជាចិត្តរបស់កម្លោះ វ៉ែរទែរ ប៉ុន្តែក៏ជាចិត្តរបស់កម្លោះអណ្តែតអណ្តូង និយមរាប់លាននាក់ ដែលមាននៅក្នុងពិភពលោកយើងនេះគ្រប់សតវត្ស និង គ្រប់ទីកន្លែង ។ គឺនៅក្នុងន័យនេះហើយ ដែលប្រលោមលោកនេះបានទទួលកិត្តិយសមកជាប់នៅក្នុងទំព័រសិល្ប៍សាកល ។

អត្តឃាតកម្មដើម្បីសេចក្តីស្នេហា ? ជារឿងមួយដែលគួរឱ្យឆ្ងល់ ចំពោះមនុស្សប្រាកដនិយម ប៉ុន្តែជារឿងមួយដែលមានន័យខ្ពង់ខ្ពស់ចំពោះមនុស្ស ដែលមានចិត្តបរិសុទ្ធក្នុងសេចក្តីស្នេហា ទោះបីចិត្តបរិសុទ្ធ នោះគ្មានន័យរឹងប៉ឹងក៏ដោយ ។ ទោះបើមាន ឬ គ្មានមូលដ្ឋានរឹងប៉ឹងក៏ដោយក៏កម្លោះ វ៉ែរទែរ ឥតរវល់ដែរ ។ គេមិនរវល់នឹងប្រាកដភាពរបស់ជីវិតមែន ប៉ុន្តែគេយកចិត្តទុកដាក់ ជាទីបំផុតនឹងប្រាកដភាពនៃមនោសញ្ចេតនា ដែលគេយកធ្វើជាន័យរបស់គេ នៅក្នុងពិភពលោក វិចារណញ្ញាណនិយមដ៏ឥតខ្លឹមសារនេះ ។ ហេតុដូចម្តេចបានជាពិភពលោកវិចារណញ្ញាណឥតខ្លឹមសារ ?- សំណួរនេះពិបាកនឹងឆ្លើយក្រៃលែង ជាពិសេសចំពោះមនុស្សដែលគ្មានមនោសញ្ចេតនាខ្ពង់ខ្ពស់ ហើយដែលយល់ថាសេចក្តីស្នេហា គ្រាន់តែជាមធ្យោបាយនៃការរស់នៅ ឬជាការសប្បាយ ផ្លូវកាយសុទ្ធសាធ ។ ប៉ុន្តែនៅក្នុងលោកយើងនេះ មនុស្សមានពីរប្រភេទគឺ មនុស្សដែលរស់នៅក្នុងអរូបិយភាពនៃមនោសញ្ចេតនា និងមនុស្សដែលរស់នៅ ក្នុងសេចក្តីត្រូវការផ្លូវសម្ភារៈ ។ បញ្ហាពិតប្រាកដដែលចោទឡើងគឺ តើគេអាច រស់នៅដោយឥតមនោសញ្ចេតនាបានទេ ? តើគូស្នេហាអាចស្នេហាគ្នាតែផ្លូវកាយ ដោយឥតមនោសញ្ចេតនាបានទេ ? តើសេចក្តីស្នេហាផ្លូវកាយអាចមាន អាយុវែងឆ្ងាយហួសពី ២ ឬ ៣ ឆ្នាំបានទេ បើគ្មានមនោសញ្ចេតនាជាមូលដ្ឋាន ? — តាមការពិតទៅ ទោះបើយើងមានគោលគំនិតប្រាកដនិយមយ៉ាងមាំមួនក៏ដោយ ក៏យើងពិបាកនឹងចាត់ទុកសេចក្តីស្នេហា ជាម៉ាស៊ីនបានដែរ ។ ទោះបើយើងខំសង្កត់ថាមពលនៃសេចក្តីស្នេហា មនោសញ្ចេតនានិយមនេះ ដើម្បីធ្វើខ្លួនយើងឱ្យទៅជាមនុស្សប្រាកដនិយមក្តី ក៏ពិបាកថានឹងអាច

ធ្វើទៅកើតបានដែរ។ **ម្យ៉ាងទៀត ដែលហៅថា មនុស្ស គឺវាខុសគ្នាពីសត្វធាតុ (les bestiaux) ត្រង់កន្លែងនេះតែម្តង**។ គឺសេចក្តីស្នេហាសត្វធាតុនិយមនេះហើយ ដែលជាមូលដ្ឋាននៃសោកនាដ- កម្មនៃប្តីប្រពន្ធ ដែលមានចរិតខុសគ្នា។ នៅក្នុងន័យនេះ ទ្រឹស្តីសម្ភារនិយមត្រូវមួយកំណាត់ទេ ។ ជាពិតណាស់ ដែលអ្នកអណ្តែតអណ្តូង និយមឱ្យតម្លៃទៅលើមនោសញ្ចេតនា ប៉ុន្តែមនោសញ្ចេតនាឥតការសេពសន្ធវៈឱ្យបានគ្រប់គ្រាន់ឆ្អែតឆ្អល់ ក៏ត្រូវតែមួយកំណាត់ដែរ។ តើធ្វើម្តេចឱ្យបានសព្វគ្រប់ ? សោកនាដកម្មនេះជាសោកនាដកម្មរបស់ប្តីប្រពន្ធតែម្តង។ **ប៉ុន្តែការដែលពិបាកគឺការបង្កើតមនោសញ្ចេតនាឱ្យបានខ្ពង់ខ្ពស់នេះឯង។** ការសេព សន្ធវៈមិនជាការពិកទេ ពីព្រោះគេអាចសិក្សាបច្ចេកទេសនេះ តាមក្បួនវេជ្ជសាស្ត្របាន។ ប៉ុន្តែ បើប្តី ឬ ប្រពន្ធ មានលក្ខណៈជាសត្វ ( bestial ) ដែលគូក៏ពិបាកដែរពីព្រោះ « ការមិនចុះ សម្រុងគ្នា » ឋិតនៅត្រង់ការខ្វះមនោសញ្ចេតនានេះ។ មនុស្សដែលកើតមកមនោសញ្ចេតនា អាចសិក្សាបច្ចេកទេសបាន ប៉ុន្តែអ្នកពូកែបច្ចេកទេស ដែលគ្មានមនោសញ្ចេតនាពិបាកនឹងធ្វើខ្លួនគេឱ្យទៅ ជាមនុស្សមនោសញ្ចេតនាណាស់។ ទាំងឡាយនេះជាចំណុចសំខាន់ៗនៃសោក នាដកម្មរវាងប្តីប្រពន្ធដែលរៀបការគ្មានឥតសេចក្តីយោគយល់ចិត្តគ្នាជាមុន។ សុភមង្គលនៃគ្រួសារនីមួយៗ - បើតាមការពិនិត្យដល់ទីជម្រៅ-គ្រាន់តែជាសុភមង្គលក្រៅៗតែប៉ុណ្ណោះ គឺ ប្តី ប្រពន្ធ ណាត់គ្នាយ៉ាងណាកុំឱ្យខូចដល់លក្ខណៈទំនៀបទំលាប់ ដែលយកអាពាហ៍ពិពាហ៍ធ្វើជារាំងនន។ មិនមែនទាំងអស់ទេ ប៉ុន្តែជាការទូទៅ ពីព្រោះសេចក្តីស្នេហារវាងប្តីប្រពន្ធ ច្រើនតែពុំសូវមានចង្វាក់ស្របគ្នា ដោយចរិត ឬ ស្ថានការណ៍ម្នាក់ៗពុំដូចគ្នា។ ទោះបីស្រឡាញ់ គ្នាពីដំបូងយ៉ាងណាក្តី ដល់យូរៗទៅម្នាក់ៗក៏បែកគំនិតរៀងៗគ្នាពីព្រោះស្ថានការណ៍ប្តូរជានិច្ច។

រឿង « ស្នេហាចុកឈាម » របស់កំឡោះ វែរទែរ ជារឿងស្នេហា មួយដ៏ប្រសើររបស់អភិជន ដែលមានទ្រព្យសម្បត្តិច្រើន ហើយដែលរស់នៅក្នុងសម្ពស្សនៃមនោសញ្ចេតនា ដោយសារទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភរបស់គេនោះ។ វែរទែរ មានសំណាងម្យ៉ាងដែរ គឺសំណាងដែលអនុញ្ញាតឱ្យគេរស់នៅក្នុងភាពទំនេរ ដែលជាប្រភពនៃការអណ្តែតអណ្តូង។ អ្នកក្រគ្មានសំណាងលេងល្បែង មនោសញ្ចេតនាដូច វែរទែរ ទេជាពិសេស ល្បែងមនោសញ្ចេតនាស្នេហាចុកឈាមរបៀបនេះ។ វែរទែរ ប្រៀបបានទៅនឹងព្រះច័ន្ទ ដែលបញ្ចេញកាំរស្មី យ៉ាងត្រជាក់ឆ្ងាយអំពីពិភពនៃព្រះធរណី ដែលពោរពេញទៅដោយភាពគ្រោតគ្រាត នៃការច្បាំងដណ្តើមបាយគ្នាចិញ្ចឹមជីវិត។ តើអ្នកណា តើអ្នកក្រណាដែលមានភ័ព្វសំណាងដូច វែរទែរ ? អ្នកឯទៀតខិតខំធ្វើការ គោរពចរិយាធម៌គ្រប់ដប់ ដើម្បីរកចំណីអាហារបរិភោគ, ចិញ្ចឹមគ្រួសារ ពោលគឺអ្នកប្រាកដនិយម ហើយឥតសម្ពស្សដែលឃ្លាតឆ្ងាយទៅៗ ពីសម្ពស្សឯកានៃព្រះច័ន្ទ ដែល វែរទែរ ជា និមិត្តរូប។ វែរទែរ អោបក្រសោបចក្រវាឡនឹងបង្កើតពិភពសួគ៌ាយ៉ាងព្រងើយកន្តើយ ដោយឥតមករវល់នឹងបញ្ហាជីវិតមនុស្សលោកអ្វីបន្តិច។ ណាង ស្ហារឡុក ក៏ស្រឡាញ់ វែរទែរ ដែរ ប៉ុន្តែនាងគ្មានលទ្ធភាពបោះបង់ចោលបញ្ហា ពិតៗរបស់មនុស្សលោកឡើយៈ នាងមានសង្សារធម្មតា រួចមករៀបការដូចគេឯង ហើយត្រូវគោរពវិចារណញ្ញាណ និងធ្វើការចិញ្ចឹម គ្រួសារដូចគេឯង។ នាងស្រឡាញ់ វែរទែរ ដែរ ប៉ុន្តែ ស្រឡាញ់ដូចមនុស្សស្រឡាញ់ព្រះច័ន្ទ។ ធម្មតាមនុស្សមានស្នេហារបៀប វែរទែរ នេះ គេច្រើនតែយកតណ្ហាដ៏ធំធេង នោះមកបម្រើសកម្មភាពដ៏ធំធេងនៃនយោបាយ ប៉ុន្តែ វែរទែរ ឥតងាករេទៅរកសកម្មភាពនេះឡើយ ហើយសុខចិត្តប្រកាន់យកជ័យជំនះក្នុងស្នេហានេះជាដាច់ខាត។ ប៉ុន្តែអ្វីទៅជ័យជំនះនោះ ?- គឺ អត្តឃាតកម្ម ! តើបានការអ្វីទៅអត្តឃាតកម្មនោះ ?- អត្តឃាតកម្មចំពោះ វែរទែរ គឺការមិនព្រមចុះចាញ់នៅមុខស្នេហា គឺការលើកតម្កល់ ស្នេហារបស់គេនោះឱ្យមានជីវិតរហូតពោលគឺ ស្នេហាអមតៈ។ វែរទែរ ប្រហែលជាគិតថា បើខ្លួនស្លាប់បាត់ទៅ នាង ស្ហារឡុក ក៏ពុំអាចរស់នៅបានសុខសាន្តជាមួយប្តីឡើយ គឺនាងលបគយគន់ព្រះច័ន្ទរាល់រាត្រី រហូតដល់ថ្ងៃស្លាប់ទៅតាម។ ឱ ! កម្លោះ វែរទែរ អ្នកចំជាឆ្កួតតែម្តង ! ប៉ុន្តែភាពឆ្កួតរវើរវាយនេះ មានសម្ពស្សណាស់ ហើយពុំមែនជាសម្ពស្សរបស់ មនុស្សលោកធម្មតាទៀត ...គឺសម្ពស្សនៃព្រះច័ន្ទ។ មុននឹងធ្វើដំណើរទៅបរលោក វែរទែរ លួចប្រាប់នាង ស្ហារឡុក ថា : « យើងគង់តែនឹងជួបគ្នាទេ... » ( «Nous nous retrouverons, balbutie-t-il, nous nous retrouverons....» ) ។ សំដីនេះ គឺជាសំដីនៃចិត្តមានៈ ... ឱចិត្តមានៈ អ្វីក៏ចិត្តមានៈម្លេះ... សុខចិត្ត សម្លាប់ខ្លួនដើម្បីយកជ័យជំនះឱ្យទាល់តែបាន ! វែរទែរ ឆ្លងពីពិភពមួយទៅ ពិភពមួយ ដូចព្រះឥន្ទ្រឆ្លងពីស្ថានមួយទៅស្ថានមួយ។ មានតែព្រះឥន្ទ្រឯណាមាន វែរទែរ ម្នាក់ទៀតដែរ ដែលភ្លេចគិតថា ខ្លួនជាមនុស្សដែលត្រូវតែរស់នៅ ក្នុងការុញ្ញភាពដូចគេឯង។ **ប៉ុន្តែ គឺចិត្តពាសមេឃនេះហើយដែលជាសម្ពស្ស** ...គ្មានអ្នកណា

លេងល្បែងឆ្កួតដូច វែរទែរ នេះបានឡើយ។ ក្រៅអំពីលោក ហ្សង់ ហ្សាក់ រូស្សូ ( J.J. Rousseàu ) ដែលមានគំនិតប្រហែលនឹង វែរទែរ សព្វថ្ងៃនេះ មាន វែរទែរ ច្រើនណាស់ គឺអ្នកដែលស្រឡាញ់តួអង្គ ( ឬតួភាព យន្ត ) James Dean ដែលជាអ្នកបន្តពូជតួអង្គ វែរទែរ (James Dean ne sera t il pas de la postérite du héros werthérien.) ។

ជាការពិតណាស់ ដែលលោក ក្លឹត មិនដូច វែរទែរ សុទ្ធសាធនោះ។ លោក ក្លឹត គ្រាន់តែសរសេររឿងស្នេហាមួយ ដែលមានកម្រឹតហួសពីសមត្ថ ភាពពិតប្រាកដរបស់គាត់តែប៉ុណ្ណោះ។ លោក ក្លឹត បានស្គាល់ជីវិតស្នេហាប្រហាក់ប្រហែលនឹងស្នេហារបស់ វែរទែរ ខ្លះដែរ ប៉ុន្តែលោក ក្លឹត ឥតបានទៅ សម្លាប់ខ្លួនលេងជាល្បែងដូច្នេះទេ។ ផ្ទុយទៅវិញ លោក ក្លឹត បានមើល « មុខ ដំបៅ » របស់គាត់ជាសះស្បើយល្អណាស់។ ពីរបីឆ្នាំបន្ទាប់ពីនិពន្ធរឿង ស្នេហា របស់កម្លោះ វែរទែរ នេះមក លោក ក្លឹត បានបញ្ជាក់ថា រឿងនេះ « គ្រាន់តែជាការលាតត្រដាងនូវការយល់សប្តិដ៏ឈឺផ្សានៃយុវភាពវិលវល់មួយ ហើយដែលជាការខ្ទរខ្ទារនៃមនោសញ្ចេតនា សាកលមួយតែប៉ុណ្ណោះ » (Cetouvrage «manifestait les rêves pénibles d’une jeunesse malade, l’ expression et l’ echo d’un sentiment universel ,………….) ។

លោក ក្លឹត ឥតស្លាប់នៅក្នុងវ័យក្មេងដូច កំឡោះ វែរទែរ ឡើយ។ លោកស្លាប់នៅក្នុងអាយុ ៨៣ ឆ្នាំ ។ ដូច្នេះរឿង វែរទែរ នេះគ្រាន់តែជាការប្រាថ្នាលេងទទេ របស់កវីដែលជាអ្នកនិពន្ធតែប៉ុណ្ណោះ ប៉ុន្តែគួរឱ្យកោតស្ញែងនូវសិល្បៈនិទានរបស់គាត់ណាស់ គឺវាដូចជារឿងដែលពិតបេះបិត។ ប៉ុន្តែបើថា រឿងប្រឌិតក៏ពុំត្រូវដែរ ពីព្រោះជារឿងដែលកើតមានមែន គឺរឿងរបស់មនុស្សម្នាក់ដែលគាត់ស្គាល់ ហើយដែលបានសម្លាប់ខ្លួន ដោយស្រឡាញ់ប្រពន្ធរបស់មិត្តភក្តិគាត់ម្នាក់ពុំបាន។ បុរសនោះ ឈ្មោះ Jerusalem ហើយនាងប្រពន្ធគេ នោះឈ្មោះ ឡុត ( Lotte ) គឺជាប្រពន្ធឈ្មោះ ហើរដ៍ ( Herd ) ដែលរស់នៅជា មួយនាង ឡុត នោះជាធម្មតា ហើយមានកូនទាំងអស់ជាង ១២ នាក់។

ទោះបើពិត ឬពុំពិតក្តី ចំណុចដែលយើងគួរកត់សំគាល់គឺ ទេពកោសល្យដ៏ប្រណិតរបស់កវី អាល្លឺម៉ង់ នេះដែលធ្វើវិភាគមនោសញ្ចេតនារបស់កំឡោះ អណ្តែតអណ្តូងនិយមយ៉ាងប្រាកដនិយមក្រៃលែង។ ចំណែកការពិពណ៌ នា ឥរិយាបថនឹងមនោសញ្ចេតនារបស់នាង ស្ហារឡុត វិញ ក៏ពុំចាកពីប្រាកដ ភាពដែរ។ នាង ស្ហារ ឡុត ដែលប្រកាន់គុណធមិយ៉ាងមាំខំបង្កើតការអស់ សង្ឃឹមក្នុងបេះដូងកម្លោះ វែរទែរ មែន ប៉ុន្តែតាមការពិតនាងឥតបោះបង់ ចោលកម្លោះបេះដូងស្រួយនេះមួយនាទីឡើយ។ លោក អង់ត្វាន់ ប្លុងដាំង (AntoineBlondin ) ក៏បានធ្វើការកត់សំគាល់ដូច្នេះដែរ។ លោកបានសរសេរ ជាអាទិ៍ថា : « នាងចិញ្ចឹមមនោសញ្ចេតនាម្យ៉ាង ដែលគេច្រឡំស្មានថា ជាគុណធមិ, នាងបង្ហាញក្នុងអាកប្បកិរិយារបស់នាងថា ការគោរពរបស់អ្នកក្រៅទាំងអស់ចំពោះនាង វាប្រសើរជាងសេចក្តីស្នេហាចំពោះមនុស្សម្នាក់ » (« La jeune fille cultive le sentiment qu’on prend facilement pour de la vertu, que l’es time de tous est preferable à l’amour d’un seul Elle n’encourage personne mais n’éloigne quiconque » )។ អាកប្បកិរិយា របស់នាង ហាក់បីដូចជា ម៉ឺងម៉ាត់ណាស់ ប៉ុន្តែនៅក្នុងជម្រៅចិត្តរបស់នាងវិញ នាងមិនដាច់ចិត្តដែរ។ រីឯ វែរទែរ វិញ ឥតព្រមចែកសុភមង្គលទៅឱ្យប្តីនាង ស្ហារឡុត ឡើយ ( Il refuse le ménage á trios ) គឺឥតព្រមឱ្យនាង ស្ហារ ឡុត ចែកសេចក្តីស្នេហាទៅឱ្យប្តីរបស់នាង សូម្បីតែបន្តិចបន្តួចឡើយ។ ប៉ុន្តែ វែរទែរ ក៏ពុំព្រមកាត់ចិត្តរបស់ខ្លួនឱ្យដាច់ស្រេចសោះឡើយ ( « Incapable de trancher, il ne sait pas non plus partager » A. Blondin ) ។

ដំណើររឿងគ្មានអ្វីវែងឆ្ងាយទេ។ គឺជារឿងនៃកម្លោះអភិជនម្នាក់ ដែលលួចស្រឡាញ់នារីស្រុកស្រែម្នាក់ នៅពេលដែលនាងជិតមានប្តី ទៅហើយ ។ កម្លោះនោះឈ្មោះ វែរទែរ ដែលទ្រព្យសម្បត្តិ អាចអនុញ្ញាតឱ្យគេដើរតួជាមនុស្សរវើរវាយ ហើយទាត់ចោលនូវប្រាកដភាពរបស់ជីវិត និងចរិយាធមិ ដែលគ្រប់គ្រងសង្គមមនុស្ស។ នារីនោះឈ្មោះ ស្ហារ ឡុត (Charlotte) មានបងប្អូនជាច្រើន ដែលនៅក្នុងបន្ទុកហើយដែលពុំអាចអនុញ្ញាតឱ្យគេដើរជាតួ អង្គរវើរវាយដូចកម្លោះ វែរទែរ បានឡើយ ទោះបើនាងលួចស្រឡាញ់កម្លោះ វែរទែរ នោះក៏ដោយ។ នាងប្រកាន់អាកប្បកិរិយា ដែលពោរពេញទៅដោយគុណធមិសព្វគ្រប់ ដែលជាហេតុធ្វើឱ្យកម្លោះ Werther កាន់តែអស់សង្ឃឹមទៅ ៗ។ តាមការពិតអាកប្បកិរិយារបស់នាង ស្ហារឡុត រិតតែបង្កើតសេចក្តីស្នេហា យ៉ាងខ្លាំងក្លាទៅវិញ នៅក្នុងបេះដូងកម្លោះ វែរទែរ ។ នៅទីបំផុត « ដើម្បីនឹង អាចរស់នៅបានក្នុងសេចក្តីស្នេហាដ៏ធំធេងនេះតទៅទៀត » វែរទែរ ក៏សម្លាប់ ខ្លួនបាត់ទៅ។

# ស្នេហាចុកឈាម
# របស់កម្លោះវែរធែរ

របស់កវី *Johann Wolfgang Gœthe*

## កំណើត នៃ សេចក្តីស្នេហា

កាលកម្លោះ Werther ចាប់ផ្តើមស្គាល់នាង Charlotte ការប្រស្រ័យ ទាក់ទងមានសភាពធម្មតា ហើយពុំអាចធ្វើឱ្យគេនឹងឃើញទៅដល់សោកនាដកម្មដ៏ធំធេងនេះសោះ។ គឺជាការទាក់ទងដែលមានជាធម្មតា រវាងកម្លោះម្នាក់ ដែលមានចិត្តពាសមេឃជាមួយនឹងនារីម្នាក់ដែលកំពុងរៀបចំខ្លួនដើម្បីរៀបការជាមួយនឹងមន្ត្រីជាន់ខ្ពស់ម្នាក់។ មុនដំបូងគ្រាន់តែមានទម្លាប់ជួបគ្នាមើលមុខ គ្នាទៅវិញទៅមកប៉ុណ្ណោះ។ ប៉ុន្តែការប្រស្រ័យទាក់ទងជា «ធម្មតា» នេះក៏បានកាឡាខ្លួនបន្តិចៗទៅជាសេចក្តីស្នេហា ។ នៅមុនពេលដែលគេនិទ្រាម្តងៗកម្លោះ Werther ចេះតែលួចនឹកថា នារីដូចរូប និងអាកប្បកិរិយានាង Charlotte នេះ ប្រសិនបើក្លាយទៅជាប្រពន្ធគេវិញ ប្រហែលជាមិនដឹង សប្បាយយ៉ាងណាទេ ។ ប៉ុន្តែ ណ្ហើយចុះ ទាក់ទងក្នុងឋានៈជាមិត្តរបស់គ្រួសារមួយក៏បានដែរ, ក៏សប្បាយដែរ, ក៏ត្រជាក់ចិត្តដែរ។ បានត្រឹមឃើញមុខនាង រាល់ថ្ងៃក៏សុខចិត្តដែរ។ គឺនៅក្នុងឋានៈនេះហើយ ដែលនាង Charlotte សុខ ចិត្តយក Werther ទៅឱ្យធ្វើជាមិត្តរបស់ប្តីនាង ។ ប្តីនាង Charlotte ឈ្មោះ អាល់ប៊ែរត៍ ( Albert ) ដែលទើបនឹងមកដល់ស្រុកនាង Charlotte ក៏មានសេច ក្តីរីករាយណាស់ដោយមានមិត្តប្រុសម្នាក់ គ្រាន់នឹងកំដរនៅក្នុងស្រុកស្រែដ៏តូចនេះ។ ប៉ុន្តែតាមការពិតទៅ "មិត្តភាពរវាងមនុស្សបីនាក់នេះ" ពុំមែនជាមិត្តភាពធម្មតាឡើយ កាលបើមានមនុស្សម្នាក់ដែលមានចិត្តរវើរវាយ និងមានៈ ដូចកម្លោះ Werther នេះ ជាសមាជិក ( On dirait plutô c'est un couple à trois )។ កម្លោះ Werther ដែលលួចស្រឡាញ់នាង Charlotte ជ្រុលទៅហើយ ពុំងាយនឹងអាចដកបេះដូងរបស់ខ្លួនវិញបានឡើយ។ កម្លោះនេះក៏ចាប់ផ្តើមច្រណែនដោយពុំដឹងខ្លួននឹងសុភមង្គលដ៏ត្រជាក់សុខសាន្តនៃគូស្វាមីភរិយាទាំង ពីរនាក់នេះ។ ដោយភ្លេចគិតទៅដល់សណ្តាប់ធ្នាប់ចរិយាធមិ ឬ បើពោលឱ្យចំទៅដោយពុំខ្វីយកចិត្តទុកដាក់នឹងចរិយាធមិដែលគ្មានសមត្ថភាពនឹងគ្រប់គ្រងបេះដូង Werther ក៏ចាប់ផ្តើមបង្ខំចិត្តនាងឱ្យមកស្រឡាញ់ តែខ្លួនម្នាក់។ តើឱ្យនាង Charlotte ធ្វើដូចម្តេច បើនាងមានប្តីទៅហើយ ប្តីនេះក៏ធ្លាប់ជាសង្សារ របស់នាងទៅទៀតកាលពីមុន។ បើឱ្យនាងស្អប់ Werther ក៏ពុំមែនជាកម្លោះម្នាក់ដែលមានចរិកគួរឱ្យស្អប់ឡើយ។ នាងខិតខំប្រកាន់អាកប្ប កិរិយាជាស្រី ដែលគោរពចរិយាធមិយ៉ាងជាក់លាក់ដើម្បីបង្កើតការអស់សង្ឃឹម នៅក្នុងបេះដូងកម្លោះ Werther។ យើងពុំអាចដឹងបានដែរថា អាកប្បកិរិយានេះមានគោលបំណងយ៉ាងណាៗទេ។ ប៉ុន្តែយើងសង្កេតឃើញថា ការបង្កើតសេចក្តីអស់សង្ឃឹមមួយនេះ នៅក្នុងបេះដូងរបស់កម្លោះរវើរវាយដូចរូប Werther នេះ វាយក្លាយទៅការបង្កើតនូវស្នេហាដ៏ខ្លាំងក្លាមួយ ដែលរីតតែមានថាមពលខ្លាំងលើសដើម។ យើងពុំអាចដឹងបានដែរថានាង Charlotte បានគិតទៅដល់ផលវិបាកនេះ ឬពុំបានគិតទេ ពីព្រោះទីមួយនាងពុំអាចនឹកស្មានថា Werther មានចិត្តមានៈដល់ម្លេះ ។ ទីពីរ នាង Charlotte ដែលបានស្គាល់ Werther អស់រយៈពេលយ៉ាងយូរដែរនោះ ក៏គួរតែយល់ចិត្ត Werther ដែរ។ ប៉ុន្តែតើឱ្យនាង ធ្វើដូចម្តេច ? ប្រគល់សេចក្តីស្នេហាទៅឱ្យកម្លោះ Werther ម្នាក់ទៀត ? នាងពុំអាចធ្វើដូច្នេះបានឡើយ ។ ប៉ុន្តែច្រាន Werther ចោលឱ្យស្រឡះតែម្តងក៏នាង ធ្វើពុំកើតដែរ។ មធ្យោបាយមានតែមួយប៉ុណ្ណោះ គឺធ្វើឱ្យ Werther អស់សង្ឃឹម ប៉ុន្តែគឺមធ្យោបាយនេះតែម្តង ដែលជម្រុញ Werther ទៅបរលោក។ កម្លោះ Werther នេះមានចិត្តមានៈណាស់ គឺឥតស្គាល់ព្រំដែនអ្វីឡើយ។ តាមធម្មតា កាលណាគេមានការខកចិត្តរបៀបនេះ គេតែងងាករេទៅធ្វើសកម្មភាពអ្វីផ្សេងទៅវិញ ដូចជាសកម្មភាពនយោបាយជាដើម។ ព្រះចៅអធិរាជណាប៉ូឡេអុង បូណាប៉ាក (Napoléon Bonaparte ) បាននិយាយថា : « នៅក្នុងរឿងស្នេហាមធ្យោបាយមានតែមួយទេ គឺខិតខំគេចឱ្យផុតពីសេចក្តីស្នេហា » ( « En amour la meilleure solution c'est la fuite » ) ។ ប៉ុន្តែកម្លោះ Werther គិតផ្សេងពីនេះទៅវិញ : គឺមិនគេចទៅធ្វើសកម្មភាពអ្វីផ្សេងៗទៀតឡើយ គេសម្លាប់ ខ្លួនគេ

ចោលតែម្តង។ តើសម្លាប់ខ្លួនដើម្បីអ្វី ? ដើម្បីនឹងបន្តសេចក្តីស្នេហាទៅទៀត ? ដើម្បីទាញចិត្តនាង Charlotte ឱ្យទាល់តែបាន ? ចំជាឆ្កួតមែន ! ប៉ុន្តែ ឆ្កួតរបៀប Werther គឺឆ្កួតក្នុងចិត្តមានៈតែប៉ុណ្ណោះ គេឥតព្រមដាក់អាវុធចុះ នៅមុខសេចក្តីស្នេហាដ៏ធំធេងនេះឡើយ ទោះបីត្រូវស្លាប់ក៏ដោយ។ រឿងនេះពុំខុសពីរឿងអ្នកស្រឡាញ់ជាតិប៉ុន្មានឡើយៈ មានអ្នកស្រឡាញ់ជាតិមិនក្លែងក្លាយខ្លះ សុខចិត្តប្តូរជីវិតដើម្បីជាតិរស់។ សេចក្តីស្នេហាទាំងពីរនេះមានកម្លាំងស្មើគ្នា។ ចំពោះស្នេហាប្រភេទទីមួយ Werther ត្រូវបានទទួលលេខមួយប្រសិន បើយើងអាចធ្វើការវិនិច្ឆ័យបាន។ ប៉ុន្តែយើងគួរចាត់ទុករឿងនេះជារឿង អណ្តែតអណ្តូងនិយម ដែលពោរពេញទៅដោយសម្ពស្សតែប៉ុណ្ណោះ។ ស្លាប់របៀប Werther នេះ គ្មានអ្នកណាអាចធ្វើបានដូចទេ ពីព្រោះជាអាកប្បកិរិយា ដែលគ្មានន័យទាល់តែសោះចំពោះសង្គមមនុស្ស ។ ប៉ុន្តែបើនិយាយអំពីលក្ខណៈបរិសុទ្ធវិញ គឺបរិសុទ្ធល្អណាស់ គឺបរិសុទ្ធដូចពេជ្រទាំងគ្រាប់ដែលមាន តម្លៃខ្ពស់មហិមា ប៉ុន្តែដែលឥតប្រយោជន៍ក៏មហិមាដែរ។ គឺការស្លាប់ដើម្បី គោលគំនិតដ៏ឥតប្រយោជន៍នេះហើយដែលមានសម្ពស្ស ពីព្រោះជាសម្ពស្ស ដែលមនុស្សលោកធម្មតាធ្វើពុំបានដូច។ ស្លាប់នៅក្នុងវ័យក្មេងដូច្នេះ ហើយ ដើម្បីរឿងស្នេហាចំកួតមួយទៅទៀត ! គួរដែរ !...

យើងអាចសន្និដ្ឋានបានដែរថានៅពេលដែលកម្លោះ Werther សម្លាប់ ខ្លួនភ្លាមនោះ នាង Charlotte ក៏វិលវល់ពុំតិចដែរ។ ប៉ុន្តែការវិលវល់នេះ ក៏ពុំអាចឋិតថេរចិរកាលឡើយ : យ៉ាងច្រើនបី ឬ បួនខែ ការសម្លាប់ខ្លួនរបស់ Werther នេះគ្រាន់តែជាអនុស្សាវរីយមួយដ៏ល្អ ហើយដ៏ក្រៀមក្រំប៉ុណ្ណោះ ចំពោះនាង Charlotte ។ នាងនៅតែបន្តការស្រឡាញ់ និង ការគោរពប្តីនាងជា និច្ច ហើយជាពិសេសការបង្កើតកូន ដែលត្រូវមានជាធម្មតាទោះបីគ្មានការទាក់ទងអ្វីជាមួយនឹងសេចក្តីស្នេហារវើរវាយក៏ដោយ។ នាង Charlotte ស្រឡាញ់ Werther ដែរ ប៉ុន្តែជាសេចក្តីស្នេហាដែលមានព្រំដែនត្រឹមត្រូវ ហើយដែល មានវិចារណញ្ញាណនៅឃ្លាំមើលជានិច្ច។ ចំពោះកម្លោះ Werther វិញ គេគ្មានវិចារណញ្ញាណអ្វីបន្តិចបន្តួចឡើយ គឺរស់នៅក្នុងមនោសញ្ចេតនាសុទ្ធសាធ ហើយឱ្យតម្លៃតែទៅលើមនោសញ្ចេតនា។ អាកប្បកិរិយានេះ និងធម្មជាតិនេះ គឺជាអាកប្បកិរិយារបស់អភិជន ដែលកើតនៅក្នុងត្រកូលអភិជន គឺកើតឡើងក្នុងការសម្បូរសប្បាយគ្មាន បញ្ហាលុយកាក់ជាឧបសគ្គ។ ស្ថានភាពនេះជាប្រភពនៃការអផ្សុក ដែលមានតែការរវើរវាយក្នុងមនោសញ្ចេតនាទេ ដែលអាចមកបំបាត់បាន ហើយបើពុំងាករេទៅធ្វើសកម្មភាពអ្វីផ្សេងទេ ការវិលវល់ក្នុងផ្លូវ មនោសញ្ចេតនានេះគ្មាននាំទៅណាឆ្ងាយពីការធុញថប់ដែលជាទ្វារនៃអត្តឃាតកម្ម។ សោកនាដកម្មនេះគេហៅថា សោកនាដកម្មអភិជន (Le drame bourgeois ) ។ ភាពទំនេររបស់ Werther ជាភាពទំនេររបស់កូនពួកអភិជនទាំងឡាយ ដែលពោរពេញទៅដោយគ្រោះថ្នាក់។

## ចិត្តវិលវល់ របស់ វែរទែរ

សោកនាដកម្មដែលកើតមានឡើងនេះ ជាសោកនាដកម្មដែលមាន មូលដ្ឋាននៅក្នុងចិត្តគំនិតរវើរវាយរបស់ វែរទែរ ដែលជាមនុស្សពុំព្រមទទួលស្គាល់សណ្តាប់ធ្នាប់របស់ចរិយាធម៌មនុស្សសាមញ្ញ។

ចិត្តរបស់ វែរទែរ ជាចិត្តដែលប្រេះឆាបាក់បែកខ្ទេចខ្ទីអស់ទៅហើយ គឺជាចិត្តដែលត្រូវភ្លើងតណ្ហាកំទេចខ្ទេចខ្ទីអស់។ កម្លោះរវើរវាយនេះ បានខំប្រឹងប្រែងគេចខ្លួនរំដោះឱ្យផុតពីការបារម្ភដ៏ធំធេងមួយ ដែលមានដក់នៅក្នុងចិត្ត គំនិតរបស់គេ។ តណ្ហាដ៏ខ្លាំងក្លាបានឆេះឆាបទាំងវិញ្ញាណទាំងមនោសញ្ចេតនា ទាំងប្រាជ្ញា និងទាំងគំនិតខូចខ្ទេចខ្ទីអស់។ ចិត្តដ៏ស្រងូតស្រងាត់បានធ្វើឱ្យគេ ទៅជាមនុស្សនៅក្នុងសង្គម ជាមួយគេឯងពុំបាន ហើយដែលជម្រុញគេឱ្យរស់ នៅតែក្នុងមនោសញ្ចេតនាអត្តទត្តមួយដ៏សង្វេគ។ ការស្រងូតស្រងាត់បានសំរេចចិត្តអោយគេតាំងខ្លួនជាមនុស្សល្អផ្តាច់គេឯង។ បើនិយាយអោយចំទៅ វែរទែរស្រឡាញ់ការឈឺចាប់ម្យ៉ាង ដែលបានលើកតម្កើងគេអោយមានលក្ខណៈខ្ពស់ជាងមនុស្សធម្មតា ។ អាល់ប៊ែរត៏ ដែលជាប្តីរបស់នាង Charlotte ក៏យល់ ឃើញដូច្នោះដែរ ។ គាត់បាននិយាយប្រាប់គេថា វែរទែរ

ស្រឡាញ់ប្រពន្ធគាត់ណាស់ ហើយពេញចិត្តនឹងបានប្រពន្ធគាត់សម្រាប់កំដរមនោសញ្ចេតនារបស់ខ្លួន វែរទែរ ចង់អោយនាង ស្ហាវឡុតលើកតម្កើងខ្លួន អោយអស់ពីចិត្តរបស់នាង ។ គេពិបាកនឹងដាក់កំហុសទៅអោយ Werther ណាស់ ជាពិសេសត្រង់ Werther ពុំព្រមអោយនាង Charlotte ចែកសេចក្តីស្នេហា និងការថ្នាក់ថ្នមទៅអ្នកណា ម្នាក់ទៀតឡើយ ទោះអ្នកនោះមានឈ្មោះថាជាប្តីក៏ដោយ ។ អាល់ប៊ែរត៍ បាននិយាយទៀតថា : « Werther នេះ ឧស្សាហ៍មកលេងផ្ទះប្រពន្ធខ្ញុំណាស់ហើយ ខ្ញុំក៏អាចចេញ ពីការសន្ទនារវាងប្រពន្ធខ្ញុំនឹង Werther ដែរ ដើម្បីទុកឱ្យ Werther បានធូរចិត្តរបស់ខ្លួន។ ខ្ញុំគ្មានស្អប់ខ្ពើម Werther អ្វីទេ ហើយខ្ញុំធ្វើ ដូច្នេះ គឺដើម្បីកុំឱ្យរំខានដល់ Werther តែប៉ុណ្ណោះ »

Werther ពុំដែលពេញចិត្តនឹងខ្លួនគេឡើយ ទោះបើគេខំលើកកំពស់ ខ្លួនគេយ៉ាងណាក៏ដោយ។ មានពេលខ្លះ ទោះបើស្រឡាញ់នាង Charlotte យ៉ាងណាក្តី Werther តែងតែ «មានខ្លួន » ដោយគេយល់ថា អាកប្បកិរិយារបស់គេ បានធ្វើឱ្យខូចដល់សុភមង្គលនៃគូស្វាមីភរិយាមួយ។ Werther ខិតខំបន្ទោសខ្លួនឯងយាស់ដែរ ប៉ុន្តែនៅពេលជាមួយគ្នានោះ មានមនោសញ្ចេតនាមួយជម្រុញគេ ឱ្យច្រណែននិន្ទានឹងប្តីនារីដែលគេស្រឡាញ់។ គេនឹកគិតថា : ចំជាចង្រៃតែម្តង ប្តីនាង ស្ហាវឡុត នេះមានសំណាងណាស់ ព្រោះមាននាង ស្ហាវឡុត ថ្នាក់ថ្នមយ៉ាងប្រណីត ប៉ុន្តែអនិច្ចាណាស់ នាងជារបស់គេ ... នាងពិតជារបស់គេទ្រាំ មិនបានទេ ពិបាកចិត្តណាស់ចុកឈាមណាស់ នាងធ្វើឱ្យខ្ញុំឆ្កួតធ្វើឱ្យខ្ញុំវិលវល់ មិនយូរទេខ្ញុំមុខជានឹងស្លាប់ដោយសារនាងជាពុំខាន ។ ត្រង់ចំណុចនេះ អាល់ ប៊ែរត៍ បានបញ្ជាក់ទៀតថា : « ដោយរឿងវាជ្រៅដល់ថ្នាក់នេះទៅហើយ មិត្ត ភាពរបស់ វែរទែរ ចំពោះខ្ញុំក៏កាន់តែធ្ងន់ធ្ងរទៅៗ ... Werther យល់ថា គឺរូបខ្ញុំ នេះតែម្តង ដែលបានឈ្លានពានទៅលើ "សិទ្ធិ " របស់គេ គឺ "សិទ្ធិ " នៃការ ស្នេហានាង Charlotte ... ជួនកាលនៅពេលដែលខ្ញុំបានយកចិត្តទុកដាក់នឹង នាង Charlotte ម្តងៗ Werther ខឹងណាស់ ប៉ុន្តែពុំដឹងធ្វើដូចម្តេច។ ខ្ញុំយល់ ដែររឿងនេះ ហើយ Werther ទ្រាំទ្រវត្តមានរបស់ខ្ញុំយ៉ាងពិបាក គេចង់ឱ្យតែខ្ញុំ ដើរឱ្យឆ្ងាយបាត់ពីគេ ពីព្រោះគេទើសទែងនឹងមុខមាត់ខ្ញុំណាស់ » ( « [……] Ne voit-il pas déjà une atteinte à ses droits dans mon attachement pour Charlotte, et dans mes attentions un secret repoche? Je m'en aperçois, je le sens, il me voit avec peine, il souhaute que je m'éloigne, ma presence lui pèse ») ។

ថ្ងៃមួយ Werther បានទទួលដំណឹងថា មានមនុស្សម្នាក់បានត្រូវធ្វើ ឃាត ។ ដំណឹងនេះបានធ្វើឱ្យ Werther រំជើបរំជួលជាអតិបរមាជាពិសេស កាលបើ Werther បានដឹងថា ឃាតកម្មនេះ បណ្តាលមកពីរឿងស្នេហា : កសិករម្នាក់រស់នៅជាមួយស្រីមេម៉ាយម្នាក់ ហើយថ្ងៃមួយនាងមេម៉ាយនោះបានយកមនុស្សម្នាក់ទៀតមកនៅជាមួយ ។ បន្ទាប់ពីមានការឈ្លោះប្រកែកជាមួយស្រីមេម៉ាយនោះ បុរសដែលទើបនឹងមកនោះ ក៏ចាកចេញពីផ្ទះបាត់ទៅ។ Werther ចាប់ចិត្ត និងយកចិត្តទុកដាក់នឹងរឿងនេះណាស់។ គេខំដើរស៊ើបយកការណ៍បន្តិចបន្តួចដោយក្តីចង់ដឹងដំណើររឿង ដែលអាចមានសភាពប្រហាក់ប្រហែលនឹងរឿងរបស់គេ។ គេខំឈរសម្លក់សពនេះយ៉ាងយកចិត្តទុកដាក់ក្រៃលែង ហើយគេខិតខំមើលមុខមាត់បុរសដ៏កំសត់នេះ ដែលស្លាប់ក្នុងការអស់សង្ឃឹមក្នុងរឿងស្នេហា។ បន្ទាប់ពីមើលសពនោះហើយ Werther ក៏និយាយតិចៗថា : « ឱអ្នកកំសត់ៗ ម៉េចក៏យ៉ាងដូច្នេះទៅវិញ... ឥតអ្នកណាយកនាង បានទេ ហើយនាងក៏លែងបោកអ្នកណាបានទៀតដែរ » ( « Qu' as-tu fait malheureux… Personne ne l'aura et elle n'aura personne » ) ។ នៅ ពេលដែលគេយកសពនោះចេញទៅ Werther ក៏បែរខ្លួនគេចយ៉ាងរហ័ស។

……………………………………………………

សេចក្តីព្រួយចិត្តរបស់ វែរទែរ នេះចេះតែរីកធំទៅៗ ជាពិសេស កាលបើឃើញគូស្វាមីភរិយានេះ រស់នៅក្នុងសុភមង្គលដ៏ប្រណីត ទោះបើគេដឹងខ្លះៗ ថា ជាសុភមង្គលដែលមានសភាពក្រៅៗតែប៉ុណ្ណោះ។ ទោះបើគិតឃើញដល់ នេះក្តី ក៏ វែរទែរ នៅតែពុំទុកចិត្តទៀត ហើយចេះតែរសាប់រសល់ដោយខ្លាចថា ជាសុភមង្គលពិតប្រាកដ។ ម្យ៉ាងទៀតគ្រោងការណ៍របស់គេដូចជា ពុំបានសម្រេចសោះ។ Werther លែងរវល់ធ្វើកិច្ចការអ្វីទាំងអស់ ហើយចាប់នេះចាប់នោះ មិនឆ្ពោះត្រង់ណា។ គេសញ្ជប់សញ្ជឹងតែក្នុងការវិលវល់ដ៏ឥតច្រកនេះ។ ការប្រស័យទាក់ទងជាមួយនាង ស្ហាវឡុត ក៏ចេះតែធ្វើឱ្យគេឈឺផ្សាខ្លាំងឡើង ៗ បើនឹងចាប់ផ្តើមធ្វើការអ្វី ក៏ធ្វើពុំកើត គឺធ្វើចុងដៃចុងជើង គ្មានប្រាកដ

ប្រជាអ្វីបន្តិចបន្តួច។ បើដេកក៏ដេកពុំលក់ បើសម្រាកក៏សម្រាកពុំកើត។ កម្លាំងពលំរបស់គេ ក៏ចេះតែអន់ថយៗទៅជាលំដាប់។ រីឯការអស់សង្ឃឹមក៏កាន់តែខ្លាំងទៅៗ ។ គេធ្វើដំណើរទៅរកមរណភាពមួយថ្ងៃបន្តិចៗ។ ជីវិតក៏កាន់តែអស់និយមទៅៗ ។ Werther បានសរសេរសំបុត្រមួយច្បាប់ទៅមិត្តរបស់គេម្នាក់ ឈ្មោះ វីលហេម ( Wilhelm ) ដើម្បីនឹងថ្លាថ្លែងអំពីការក្រៀមក្រំរបស់គេ។ សំបុត្រនោះមានសេចក្តីដូចតទៅ : « សម្លាញ់ វីលហេម ! សព្វថ្ងៃនេះខ្ញុំកំពុង នៅក្នុងស្ថានភាពមួយ ដែលមានលក្ខណៈប្រហែលនឹងស្ថានភាពរបស់មនុស្ស កំសត់ដែលហាក់បីដូចជាមានពន្លឺគំនិតឆ្លាត មិនស្រួលមួយមកសណ្ឋិត។ គំនិតនោះចេះតែមកញាំញីខ្ញុំជារឿយៗ។ គំនិតនោះពុំមែនជាការបារម្ភអ្វីទេ ប៉ុន្តែក៏ពុំមែនជាការប៉ុនប៉ងអ្វីជាក់លាក់ដែរ គឺជាកំហឹងផ្ទៃក្នុងម្យ៉ាងរកយល់ពុំឃើញ ដែលកំពុងតែហែកវក់វីដើមទ្រូងរបស់ខ្ញុំ ហើយដែលធ្វើឱ្យខ្ញុំឈឺចាប់ ឈឺចាប់ជាអតិបរមា, ដោយការឈឺចាប់នេះ ខ្ញុំក៏វង្វេងទិសតំបន់ ពុំដឹងរកច្រកចេញ តាមណា គឺហាក់បីដូចជាឆាកដ៏ងងឹតស្លុបនៃស្បែរាត្រី ហើយឆាកដ៏ងងឹតស្លុបនោះ មានសភាពដូចជារដូវចម្រៃមួយរបស់មនុស្សលោក »។

« ពីល្ងាចម្សិលមិញ ដោយទ្រាំពុំបានខ្ញុំក៏ចេញទៅក្រៅ ។ ផ្ទាំងទឹកកក ទាំងឡាយក៏ចាប់ផ្តើមរលាយយ៉ាងខ្លាំង។ ខ្ញុំបានឮសួរគេនិយាយថា ទឹកស្ទឹងបានលិចហូរហៀរ, អូរទាំងឡាយក៏ពោរពេញទៅដោយទឹក ហើយចាប់តាំងពីត្រឹម Wahlhem ទៅទឹកលិចខ្ទេចខ្ទីអស់ហើយ បានគ្របដណ្តប់ទាំងជ្រលង ជាទីស្នេហារបស់ខ្ញុំទៀត ។ ពេលយប់នៅម៉ោងដប់មួយ ខ្ញុំក៏បានរត់ទៅកន្លែងនោះ។ ទស្សនីយភាពឃើញគួរឱ្យរន្ធត់!...នៅក្រោមពន្លឺព្រះចន្ទ្រមើលពីលើក កំពូលផ្ទាំងសិលាទៅ គេឃើញទឹកជ្រោះ ហូរពាសពេញទាំងចំការវាលរបងផ្ទះលិចពាសពេញទាំងអស់ ហើយចន្លោះភ្នំទាំងឡាយ ក៏បានក្រឡាប់ផ្កាប់ផ្ងារអស់ខ្ទេចខ្ទី គេឃើញតែទឹកសមុទ្រដ៏ខ្ជួលខ្ជាញ់ ដែលកំពុងតែត្រូវខ្យល់យ៉ាងស្រួចបក់បោកយ៉ាងខ្ទរខ្ទារ ... នៅពេលដែលព្រះចន្ទ្របានចេញមកជាថ្មីម្តងទៀត ហើយនៅនឹង ថ្កល់ពីលើដុំពពកខ្មៅមួយ ពន្លឺការស្មីមួយយ៉ាងល្អ ហើយគួរឱ្យខ្លាចបាន ចែងចាំងម្តងទៀត ទៅលើរលកទឹកដែលមកវាយផ្ទប់យ៉ាងខ្ទាំខ្ទរនៅចុងជើងខ្ញុំ ខ្លួនខ្ញុំឡើងព្រឺអស់សពាង្គកាយ រួចមកចំណង់មួយក៏ចាប់គួចផ្តើមឡើង ... យី ! ដៃខ្ញុំទាំងពីរក៏លាតសន្ធឹងឡើង ដោយខ្ញុំឈរនៅជិតជ្រោះស្រាប់ផង ដង្ហើមខ្ញុំ ដកសឹងពុំដល់គ្នាផង ខ្ញុំចង់តែលោតទៅក្នុងជ្រោះនោះយ៉ាងពេញទំហឹង គឺ លោតឱ្យបាត់ខ្លួនទៅតែម្តង ! ខ្ញុំក៏បណ្តែតអារម្មណ៍យ៉ាងសែនមនោរម្យមួយទៅក្នុងការវិលវល់និងក្នុងការឈឺចាប់ របស់ខ្ញុំ ខ្ញុំហាក់បីដូចជាឃើញខ្លួនខ្ញុំ កំពុងតែបុកផ្ទប់ទៅក្នុងសន្ទាប់ដ៏គគ្រឹកគគ្រេងនៃរលកទឹក។ អស្ចារ្យមែន គឺ ហាក់បីដូចជាលើកជើងពុំរួចហើយផ្តួលខ្លួនទៅក្នុងការចុកចាប់ទាំងឡាយ ( ...) ឱសម្លាញ់អើយ ! ខ្ញុំចង់តែយកជីវិតរបស់ខ្ញុំទាំងមូលទៅកំទេចដុំពពកដ៏ខ្មៅងងឹត ហើយដ៏ធ្ងន់ នឹងទៅចូកទឹករលកទាំងនោះ ចេញជាមួយនឹងកម្លាំង ខ្យល់ព្យុះសង្ឃរានេះ.... តើភាពដ៏មនោរម្យនេះ អាចទៅជាព្រំដែននៃមនុស្ស ម្នាក់ដែលកំពុងតែអផ្សុកតប់ប្រមល់នៅក្នុងគុករបស់គេបានទេ ? »

« ខ្ញុំបានដាក់ភ្នែកយ៉ាងស្រងូតស្រងាត់មើលទៅកន្លែងដែលខ្ញុំធ្លាប់តែ សម្រាកជាមួយ ស្ហារឡុត នៅនៅក្រោមដើមសូលមួយ បន្ទាប់ពីនាំគ្នាដើរលេងនៅក្រោមកំដៅ។ កន្លែងនោះទៀតក៏លិចខ្ទេចខ្ទីអស់ដែរ ហើយខ្ញុំមើលដើម សូលនេះសឹងតែពុំស្គាល់។ ខ្ញុំក៏គិតថា : « ទីវាលនេះ ហើយនិងកន្លែងដែលនៅ ជុំវិញផ្ទះដែលខ្ញុំសំណាក់ ប្រហែលជាត្រូវទឹកជ្រៅកំទេចបាក់បែកអស់គ្មានសល់ទេ បាក់បែកខ្ទេចខ្ទីអស់ហើយទ្រនំដ៏សុខរបស់យើង ! » ហើយពន្លឺដ៏ក្រហម ច្រាលនៃអតីតកាលក៏ចែងចាំងឡើង នៅក្នុងព្រលឹងរបស់ខ្ញុំ... ( ...) ខ្ញុំឈរនឹងថ្កល់នៅកន្លែងនោះ... ខ្ញុំគ្មានខឹងខ្លួនខ្ញុំអ្វីឡើយ ពីព្រោះខ្ញុំមានសេចក្តីក្លាហានគ្រប់គ្រាន់ដើម្បីស្លាប់... ខ្ញុំគួរតែ... ឥឡូវនេះខ្ញុំបានធ្លាក់ខ្លួនទៅដូចជាយាយចាស់ម្នាក់ ដែលដើររើសឧសនៅតាមរបងផ្ទះ ហើយដើរសុំអាហារនៅតាមផ្ទះ គេគ្រាន់នឹងបានបន្តនឹងបន្ធូរជីវភាពដ៏ក្រៀមក្រំ និងដុនដាបរបស់ខ្លួន » ។

ថ្ងៃទី ១៤ ធ្នូ

« ឱសម្លាញ់អើយ ! ខ្ញុំពុំដឹងថារឿងរ៉ាវទាំងអស់នេះមានសភាពដូច ម្តេចទេ ? ខ្ញុំចុះផ្ទាក់ដល់ខ្លាចទាំងខ្លួនឯងទៀត។ សេចក្តីស្នេហាដែលខ្ញុំមានចំពោះនាង គឺជាសេចក្តីស្នេហាមួយដ៏ជាទីគោរពដ៏បរិសុទ្ធ និងដ៏ជិតស្និទ្ធជាទីបំផុត ។ ខ្ញុំពុំដែលមានចំណង់ដ៏ខុសឆ្គងអ្វីឡើងនៅក្នុង

ព្រលឹងរបស់ខ្ញុំ [. . ] យប់ នោះឯង មិត្តអើយ ខ្ញុំសឹងពុំហ៊ាននិយាយប្រាប់មិត្តឡើយ ពីព្រោះខ្លួនខ្ញុំឡើង ញ័រចំប្រប់អស់... ខ្ញុំអោបនាងយ៉ាងស្អិតផ្ទប់នឹងដើមទ្រូងរបស់ខ្ញុំ ខ្ញុំខ្ទប់មាត់នាង ដែលញ័រទទ្រើកដោយក្ដីស្នេហា គឺខ្ញុំយកមាត់របស់ខ្ញុំទៅខ្ទប់ ហើយថើបនាង គ្មានឆ្អែតឆ្អល់។ ភ្នែករបស់ខ្ញុំម្ខាង ស្រវឹងទៅក្នុងក្រសែភ្នែករបស់នាង។ ឱព្រះ អើយ ! តើជាអំពើឧក្រិដ្ឋឬ បើខ្ញុំក្រេបជញ្ជក់យកសុភមង្គលនេះពុំឈប់ឈរហើយបើខ្ញុំនឹកទៅដល់ពេលដ៏សប្បាយដ៏ខ្លាំងក្លាទាំងប៉ុន្មាននេះ ? ស្ហារឡុតអូន ! ស្ហារឡុតអូន ! ... បងធ្លាក់ខ្លួនហើយ វិញ្ញាណរបស់បងទាំងប៉ុន្មានវិលវល់អស់។ ប្រាំបីថ្ងៃមកហើយដែលខ្ញុំលែងនឹកនាឃើញអ្វីទាំងអស់។ ភ្នែករបស់ខ្ញុំ ពោរពេញទៅដោយទឹកនេត្រា។ ខ្ញុំពុំដឹងជានៅទីណាទេ ហើយខ្ញុំហាក់ដូចជានៅគ្រប់ទីកន្លែងទាំងអស់ ... ខ្ញុំឥតចង់ប្រាថ្នាអ្វី ហើយឥតមានចំណង់អ្វីទៀតទាំងអស់។ ខ្ញុំមានផ្លូវតែមួយគត់ទេ គឺចាកចេញឱ្យបាត់ពីកន្លែងនេះតែម្ដង» ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

នៅទីបំផុត ការសម្រេចចិត្តធ្វើដំណើរទៅកាន់បរលោក បានមកវិល វល់ពេញដួងព្រលឹងរបស់ Werther។ បន្ទាប់ពីបានជួបនាងស្ហារឡុត នៅពេលចុងក្រោយបង្អស់ Werther ឃើញមានផ្លូវតែមួយគត់ គឺសម្លាប់ខ្លួនឱ្យបាត់តែម្ដង។ គំនិតនេះជាសេចក្ដីសង្ឃឹមចុងក្រោយរបស់គេ។ ប៉ុន្តែគេបានប្ដេជ្ញាថា នឹងមិនសម្លាប់ខ្លួននៅក្នុងកំហឹងឡើយ គឺសម្លាប់ខ្លួនក្នុងចិត្ត ដ៏ស្ងប់ស្ងាត់ជាទីបំផុត បន្ទាប់ពីធ្វើការសម្រេចចិត្តមួយយ៉ាងមាំ។ នៅក្នុងចិត្តរបស់គេ Werther ពុំទាន់បាត់វិលវល់នៅឡើយទេ។ Werther បាន សរសេរសំបុត្រចុងក្រោយបង្អស់មួយ ទុកសម្រាប់មិត្តរបស់គេមុននឹងចាកដំណើរទៅបរលោក។ សេចក្ដីសំបុត្រនោះមានដូចតទៅ :

« វត្តមានរបស់នាង ព្រហ្មលិខិតរបស់នាង សេចក្ដីយកចិត្តទុកដាក់ របស់នាងចំពោះខ្ញុំ បានចេញមកជាដំណក់ទឹកនេត្រាចុងក្រោយបង្អស់នៃខួរ របស់ខ្ញុំដែលខូចខ្ទេចខ្ទីទៅជាធ្យូងស្រេចទៅហើយ។

« បើកវាំងននៃឆាកល្ខោន ហើយរត់ទៅពួននៅក្រោយវាំងននោះ ...រឿងទាំងនោះក៏ចប់ត្រឹមនោះឯង ! តើញាប់ញ័របានការអ្វី ? តើញញើត បានការអ្វី ? ពីព្រោះគេពុំដឹងថាមានអ្វីនៅពីក្រោយឬ ? ... ពីព្រោះគេលែង បានវិលត្រឡប់មកវិញឬ ? ... មនុស្សយើងតែប៉ុណ្ណឹង គឺឃើញតែការវិលវល់ និងភាពងងឹតស្លុប ត្រង់កន្លែងណាដែលយើងពុំដឹងច្បាស់ថា តើមានអ្វី » ។

ថ្ងៃទី ២០ ធ្នូ ( សំបុត្រចុងក្រោយបង្អស់ )

« វីលហេម ជាទីស្រឡាញ់, ខ្ញុំអរគុណមិត្រណាស់ ដែលបានផ្ដល់យោបល់មកឱ្យខ្ញុំ។ មិត្តនិយាយហ្នឹងត្រូវហើយ។ ខ្ញុំត្រូវតែចាកចេញឱ្យផុត។ មិត្របានធ្វើសំណូមពរ ឱ្យខ្ញុំមករស់នៅជាមួយមិត្រ ប៉ុន្តែការស្នើនេះ វាពុំស៊ីនឹងធម្មជាតិរបស់ខ្ញុំទាំងអស់ទេ : យ៉ាងហោចណាស់ក៏ខ្ញុំត្រូវរុករកកេរបន្ដិចដែរ ជាពិសេសនៅពេលដែលយើងកំពុងតែសង្ឃឹមថា នឹងមានភាពត្រជាក់មួយយ៉ាងយូរនឹងផ្លូវដ៏ល្អ។ ។ ម្យ៉ាងទៀតខ្ញុំសប្បាយចិត្តណាស់ ដោយមិត្រគិតថានឹងមករកខ្ញុំ។ ប៉ុន្តែសូមមិត្រចាំដល់ប្រាំថ្ងៃទៀតចុះ ហើយចាំទទួលសំបុត្រខ្ញុំមួយទៀតសិន ខ្ញុំនឹងប្រាប់ដំណឹងខ្លះដែលនឹងមានកើតឡើង។ គេពុំត្រូវបេះផ្លែឈើ ដែលពុំទាន់ទុំទេ ហើយលើសពីដប់ប្រាំថ្ងៃ ឬតិចជាងដប់ប្រាំថ្ងៃ វាខុសគ្នាឆ្ងាយណាស់។ ឯងជួយប្រាប់ម្ដាយគ្នាផងថា ឱ្យជួយបន់ឱ្យកូនគាត់ផង ហើយសូមឱ្យគាត់មេត្តាអភ័យទោសឱ្យខ្ញុំផង អំពីទុក្ខសោកទាំងប៉ុន្មានដែលខ្ញុំបានផ្ដល់ទៅឱ្យគាត់។ គឺជាកម្មរបស់ខ្ញុំទេ ដែលកើតមកសម្រាប់តែផ្ដល់ទុក្ខទោសទៅឱ្យមនុស្ស ដែលខ្ញុំគួរតែផ្ដល់សេចក្ដីសប្បាយសោះ។ លាហើយមិត្រជាទីស្រឡាញ់។ សូម ឱ្យព្រះជួយថែរក្សាឯងឱ្យបានជីតដល់ ។ លាហើយ »

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

នៅថ្ងៃដែល Werther សរសេរសំបុត្រចុងក្រោយនេះ គេបាន សម្រេចចិត្តមកលេងផ្ទះនាង ស្ហារឡុត មង្គទៀត។ នៅថ្ងៃនោះនាងស្ហារ ឡុត នៅផ្ទះម្នាក់ឯង ហើយដោយជិតថ្ងៃណូអែលផង នាងកំពុងរៀបចំអំណោយជា អនុស្សាវរីយ៍ ដើម្បីឱ្យទៅប្អូនរបស់នាង។ Werther ក៏ឆ្លៀតនិយាយបញ្ឆិតបញ្ឆៀងទៅនាង Charlotte ដោយខំញញឹមយ៉ាងស្អាតថា : « នាង Charlotte ឯងក៏មុខជានឹងបានទទួលរង្វាន់មួយនឹង

គេដែរ ប្រសិនបើនាងនៅកាន់អាកប្បកិរិយាស្លូតបូត, នាងនិងបានទៀនមួយយ៉ាងតូច ហើយនឹងអ្វីៗផ្សេងៗទៀត — ហើយនាងដឹងទេថាពាក្យស្លូតបូត មានន័យថាម៉េច ? នាង Charlotte ក៏របូតមាត់ឡើង, តើខ្ញុំត្រូវប្រកាន់អាកប្បកិរិយាបែបណា ? — តើខ្ញុំអាចកាន់អាកប្បកិរិយាបែបណាបាន នាង Charlotte ជាទីមេត្រី ? — នាងក៏និយាយបន្តម្តងទៀត : ល្ងាចថ្ងៃព្រហស្បតិ៍នេះ ជាថ្ងៃដែលគេរៀបចំបុណ្យណូអែល, ពួកក្មេងៗវានឹងមក ហើយឪពុកខ្ញុំក៏នឹងមកជាមួយដែរ, ម្នាក់ៗនឹងបានទទួលអំណោយមួយៗម្នាក់។ Werther ឯងក៏មកលេងដែរណា៎ .... ប៉ុន្តែកុំមកមុនណា៎...» ដោយឮសូរពាក្យចុងក្រោយនេះ Werther ភ្ញាក់ព្រើតរកនិយាយអ្វីពុំរួច។ នាង Charlotte ក៏និយាយតទៅទៀតថា : « អញ្ចឹងចុះណា៎។ រឿងហ្នឹង វាត្រូវតែអញ្ចឹង, សុំអត់ទោសឱ្យខ្ញុំផង ទុកឱ្យខ្ញុំបានសុខសិនទៅ។ បន្តទៅទៀតមិនបានទេ, ទេបន្តទៅទៀតមិនបានទេ » ។ Werther ងាកមុខចេញពីនាង ហើយក៏ដើរមួយៗ ដោយបោះជំហានយ៉ាងវែងៗ ទៅក្នុងបន្ទប់ដោយនិយាយពាក្យនាង Charlotte ទាំងខាំធ្មេញថា : « បន្តទៅទៀតមិនបានទេ ! »។ លុះឃើញប្រតិកម្មរបស់ Werther ខ្លាំងពេក ដូច្នេះនាង Charlotte ក៏ខំរកពាក្យ និងសំណួរផ្សេងៗមកនិយាយបន្ទប់ ។ ប៉ុន្តែជាការឥតប្រយោជន៍។ Werther និយាយតបទៅវិញថា : « Charlotte ខ្ញុំឥតវិលត្រឡប់មកជួបនាងវិញទេ ! » ។ នាង Charlotte ក៏សួរទៅវិញថា : « ម៉េចអញ្ចឹង Werther ? ត្រូវតែមក វិញ, Werther ឯងអាចមកវិញ, ប៉ុន្តែសូមខំតាំងចិត្តបន្តិចទៅ ! ឱ Werther ! ចុះហេតុដូចម្តេចក៏អ្នកមានចិត្តខ្លាំងក្លាម្ល៉េះអ្វីៗ ដែលអ្នកជួបប្រទះអ្នកយកតណ្ហារបស់អ្នកមកគ្របដណ្តប់ភ្លាម »។ នាង ស្លារឡុត ស្ទុះទៅចាប់ដៃ Werther ហើយនិយាយបន្ថែមទៀតថា : « ខំតាំងចិត្តបន្តិចទៅណា៎ អ្នកមានប្រាជ្ញាខ្លាំងក្លាណាស់ មានទេពកោសល្យខ្ពង់ខ្ពស់ណាស់ មានចំណេះវិជ្ជាច្រើនណាស់ ! តាំងខ្លួនជាមនុស្សឡើងបណ្តាច់ចិត្តចេញអំពីព្រហ្មលិខិតនេះទៅដាច់ចិត្តចេញពីមនុស្សម្នាក់ដែលពុំព្រមទទួលនូវឥរិយាបថរបស់អ្នកនេះទៅ ! » ។ Werther សង្កៀតធ្មេញ ហើយសម្លឹងមើលទៅនាង ស្លារឡុត ដោយស្រងូតស្រងាត់យ៉ាងខ្លាំង។ ណាង ស្លារឡុត ចាប់ដៃ Werther ជាប់ ហើយនិយាយទៀតថា : « ខំប្រឹងទប់ចិត្តបន្តិច ទៅតែមួយពេលទេ ។ Werther ឯងដឹងខ្លួន ថាអ្នកកំពុងតែរត់យ៉ាងលឿនទៅរកការស្លាប់ គឺរត់នៅក្នុងឆន្ទៈមួយយ៉ាងមុាំបំផុត ? ចុះហេតុដូចម្តេចក៏ Werther មកស្រឡាញ់ខ្ញុំទៅវិញ ខ្ញុំជារបស់គេ ទៅហើយណា៎ ? ខ្ញុំខ្លាចក្រែង ខ្ញុំបារម្ភខ្លាចក្រែង Werther ស្រឡាញ់ខ្ញុំយ៉ាងខ្លាំងក្លាដូច្នេះ មកតែ ពីរឿងហ្នឹងតែមង្គ គឺរឿងហ្នឹងហើយ ដែលធ្វើឱ្យចំណង របស់ Werther ឯង មានសម្ពស្ស ! »
( « (….. ) Ne sentez-vous pas que vous vous abusez, aue vous courez volontairement à votre perte? Pourquoi faut-il que ce soit moi, Werther ! moi qui appartiens à un autre, précisément moi ? Je crains bien, oui, je crains que ce ne soit cette impossibilité même de m’obtenir qui fasse le charme de vos desires ! » )។ វែរទែរ កន្ត្រាក់ដៃ ចេញពីដៃនាង ស្លារឡុត ហើយសម្លក់នាងជាប់បញ្ចេញនូវការក្នាញ់ ហើយក៏និយាយថា : ˝ស្លូតបូតមែន ! ស្លូតមែនមែន ! ការកត់សំគាល់នេះគ្មានអ្វីក្រៅ ពីការកត់សំគាល់របស់ អាល់ប៊ែរត៍ទេ ! ពូកែនិយាយមែន ! យីពូកែនិយាយ មែន—នាង ស្លារ ឡុត និយាយតបថា : អ្នកណាក៏អាចនិយាយអញ្ចឹងបានដែរ ។ តើក្នុងមួយពិភពលោកទាំងមូលគ្មាន នារីណាម្នាក់ទៀតទេឬ ដែលអាចឆ្លើយទៅនឹងចិត្តរបស់ Werther ឯង ? Werther ឯងត្រូវគិតថា ត្រូវតែរកនារីនោះឱ្យឃើញ ហើយខ្ញុំជឿជាក់ថា Werther ឯងមុខតែនឹងរកឃើញជាពុំខានឡើយ។ ជាយូរណាស់មកហើយ ចំពោះអ្នកនិងចំពោះខ្ញុំភាពឯកឯងរបស់ វែរទែរឯងនេះ ធ្វើឱ្យខ្ញុំពិបាកចិត្តក្រៃលែង ។ [...] បើ Werther ឯង ធ្វើមើលប្រហែលជានឹងបានធូរចិត្តជាពុំខាន។ Werther ឯងរកទៀតទៅត្រូវហាត់ចិត្តរករបស់អ្វីមួយ ដែលសមនឹងសេចក្តីស្នេហារបស់ វែរទែរ ឯង ។ បើ រកឃើញហើយ Werther ឯងត្រឡប់មកវិញចុះ យើងនឹងរស់នៅក្នុង សុភមង្គលមិត្តភាពមួយយ៉ាងស្មោះស។ - Werther ក៏ឆ្លើយថា : ˝ ហ្នឹងហើយ យើងអាចយកការញញឹមយ៉ាងល្វីងចត់មួយ ទៅបោះត្រានៅលើមិត្តភាពនោះ ហើយយកទៅឱ្យគ្រូ យកទៅបង្រៀនបន្តទៅទៀត។ ស្លារឡុត ទុកឱ្យខ្ញុំបាន ស្ងៀមស្ងប់បន្តិចទៅចុះ :ស្ថានការណ៍គង់តែនឹងប្តូរទេ ! ˝។

ស្លារឡុត និយាយថា : ˝ Werther ឯងកុំមកមុនបុណ្យណូអែល ណា៎ ˝ ។ Werther រៀបតែនឹងឆ្លើយតបទៅវិញ ប៉ុន្តែអាល់ប៊ែរត៍ក៏ចូលមកដល់។ គេធ្វើគារវកិច្ចគ្នាទៅវិញទៅមកនៅក្នុងបរិយាកាសមួយយ៉ាងស្ងួតជាទីបំផុត។ គេនាំគ្នាដើរចុះឡើងជិតគ្នាពេញក្នុងបន្ទប់ដោយ

ពិបាកចិត្តវេវៀងៗខ្លួន ។ Werther ខំនិយាយអំពីរឿងផ្សេងៗ ដែលគ្មានន័យទាល់តែសោះ ដើម្បីបន្លប់ ប៉ុន្តែដោយទ្រាំមិនបានក៏ឈប់និយាយតទៅទៀតទៅ ។ អាល់ប៊ែរត៍ ក៏ឈប់ និយាយដែរ, ហើយក៏សួរទៅប្រពន្ធខ្លួនអំពីកិច្ចការផ្សេងៗ ដែលខ្លួនបានប្រគល់ឱ្យធ្វើ។ ដោយនាង ស្ហារឡុត និយាយប្រាប់វិញថា ពុំទាន់បានធ្វើនៅឡើយ អាល់ប៊ែរត៍ ក៏និយាយតបដោយប្រើសំដីស្ងួត ហើយម៉ឺងម៉ាត់ទៀត។ Werther ក៏សង្កេតឃើញនូវស្ថានភាពនេះដែរ។ គេក៏ចង់រៀបលាដែរ ប៉ុន្តែរកឱកាសពុំបាន។ ស្ថានភាពនេះបន្តអស់រយៈពេលយ៉ាងយូរ។ នៅម៉ោងប្រាំបី គេក៏ចាប់ផ្តើមក្រពុលមុខតែមង្ក។ នៅពេលដែលគេកំពុងរៀបចំបរិភោគអាហារពេល ល្ងាច Werther ក៏ដើរទៅយកឈើច្រត់នឹងមួយបំរុងនឹងលាអ្នកផ្ទះ។ ប៉ុន្តែ អាល់ប៊ែរត៍ឃាត់ឱ្យនៅបរិភោគជាមួយគ្នា, ដោយ Werther យល់ឃើញថា ការឃាត់នេះ គ្រាន់តែជាការគួរសមប៉ុណ្ណោះ គេក៏អរគុណយ៉ាងស្ងួតទៅវិញ ហើយចេញបាត់ទៅ។

នៅពេលដែលគេត្រឡប់ទៅដល់ផ្ទះវិញ Werther ក៏ឡើងតែម្នាក់ ឯងទៅក្នុងបន្ទប់គេ។ វែរទែរ យំសោកបោកខ្លួន ហើយនិយាយខ្លួនឯងយ៉ាងខ្លាំងៗ ។ គេដើរចុះដើរឡើងក្នុងបន្ទប់ដោយជំហានវែងៗ រួចក៏លោតទៅលើគ្រែទាំងសម្លៀកបំពាក់។ ឈ្នួលបំរើដោយឃើញដូច្នេះក៏ដើរចូលទៅក្រែង វែរទែរ ប្រើឱ្យដោះស្បែកជើង។ វែរទែរ ក៏ឱ្យឈ្នួលបំរើនោះដោះស្បែកជើង ប៉ុន្តែប្រាប់ទៅវិញថា ស្អែកព្រឹកនេះបើចូលមកក្នុងបន្ទប់ត្រូវគោះទ្វារហៅជាមុនសិន។

នៅព្រឹកថ្ងៃច័ន្ទទី ២៦ ធ្នូ វែរទែរ ក៏សរសេរសំបុត្រមួយទៅនាង ស្ហារឡុត ដែលមានសេចក្តីខ្លះៗ ដូចខាងក្រោមនេះ ។ សំបុត្រនេះដាក់នៅលើតុដែល វែរទែរ ស្លាប់ ហើយបានត្រូវគេប្រគល់ទៅឱ្យនាង ស្ហារឡុត :

« ខ្ញុំដាច់ចិត្តស្រេចអស់ហើយ, ខ្ញុំចង់ស្លាប់ណាស់ ហើយខ្ញុំសរសេរ សំបុត្រមកអ្នកនេះ ដោយគ្មានការរវើរវាយអណ្តែតអណ្តូងបន្តិចបន្តួចឡើយ គឺសរសេរនៅក្នុងស្មារតី និង សតិយ៉ាងមាំបំផុត, គឺសរសេរនៅថ្ងៃដែលខ្ញុំត្រូវជួបអ្នកជាលើកចុងក្រោយបង្អស់។ នៅពេលដែលអ្នកអានសំបុត្រនេះ ស្ហារឡុត ជាទីមេត្រី, គេកំពុងតែកាយដីកប់ខ្មោចដ៏ត្រជាក់ស្ងួតរបស់មនុស្សកំសត់ម្នាក់ ដែលពុំអាចរកសេចក្តីសុខក្នុងផ្លូវចិត្តបាន ហើយដែលពុំអាចស្គាល់ការសប្បាយដ៏ត្រជាក់ចិត្ត ក្រៅអំពីការសន្ទនាជាមួយអ្នកនៅពេលមុនការស្លាប់របស់គេ។ យប់នេះចិត្តរបស់ខ្ញុំវិលវល់ក្រៃលែង ប៉ុន្តែការវិលវល់នេះធ្វើឱ្យខ្ញុំត្រជាក់ចិត្តជាទីបំផុត ! រាត្រីនោះ បានធ្វើឱ្យការសម្រេចចិត្តរបស់ខ្ញុំមាំហើយខ្លាំងទៀត។ ខ្ញុំចង់ស្លាប់ ! ពីម្សិលមិញ នៅពេលដែលខ្ញុំផ្តាច់ចិត្តចេញពី ស្ហារឡុត ឯងវិញ្ញាណរបស់ខ្ញុំឡើងកញ្ច្រោល ហើយបេះដូងរបស់ខ្ញុំស្ទើរគាំង ! ជីវិតរបស់ខ្ញុំ ដែលឆេះខ្លោចជិតអស់ទៅហើយ នៅជិតនាងគឺគ្មានសេចក្តីសង្ឃឹម ហើយត្រជាក់ស្រឹម។ ទិដ្ឋភាពទាំងឡាយនេះធ្វើឱ្យខ្ញុំស្អប់ ហើយខ្លាចផង ! ខ្ញុំខំត្រដរ ដើរមកដល់បន្ទប់ខ្ញុំយ៉ាងពិបាក។ ខ្ញុំលុតជង្គង់ពោរពេញទៅដោយកំហឹង,ឱ ព្រះ អើយសូមឱ្យទឹកភ្នែកដ៏ល្វីងជូរចត់របស់ខ្ញុំបានធូរស្រាលផង នៅពេលចុងក្រោយបង្អស់នេះ។ គ្រោងការនិងគំនិតជាច្រើនរបស់ខ្ញុំ បានមកហែកហួរព្រលឹងរបស់ខ្ញុំ, ហើយនៅទីបំផុតនៅសល់តែគំនិតមួយគត់ ដែលមានសណ្ឋិតនឹងថ្កល់ ហើយដែលមានលក្ខណៈរឹងប៉ឹង គ្មានអ្វីរជួយបាន : ខ្ញុំចង់តែស្លាប់មួយ មុខប៉ុណ្ណោះ ! ខ្ញុំក៏ប្រាសខ្លួនទៅលើគ្រែបាត់ទៅ, នៅព្រឹកមិញនេះ ខ្ញុំក្រោក ឡើងក្នុងភាពស្ងៀមស្ងប់មួយយ៉ាងស្អាត ហើយការសម្រេចចិត្តរបស់ខ្ញុំនៅរឹង ប៉ឹងជានិច្ចនៅក្នុងបេះដូងរបស់ខ្ញុំ ខ្ញុំចង់ស្លាប់ !...... ពុំមែនជាការអស់សង្ឃឹម ទេ ប៉ុន្តែជាគំនិតមួយយ៉ាងរឹងប៉ឹងជាទីបំផុតដែលប្រាប់ខ្ញុំថា គ្មានផ្លូវណាទៀត ឡើយក្នុងជីវិតខ្ញុំ ហើយខ្ញុំស្លាប់នេះ គឺស្លាប់ដើម្បីនាងតែប៉ុណ្ណោះ។ គឺអញ្ចឹង មែនណា៎ ស្ហារឡុត តើលោកបានការអ្វី ? ក្នុងចំណោមយើងទាំងបីនាក់ ត្រូវតែមានម្នាក់ដើរចេញជាដាច់ខាត ហើយខ្ញុំក៏សម្រេចដើរចេញខ្លួនឯងតែមង្ក។ ស្ហារឡុត ជាទីមេត្រី ! គំនិតមួយពោរពេញទៅដោយកំហឹង បានមកចាក់ស្រេះ នៅក្នុងបេះដូងដ៏រហែកខ្ទេចខ្ទីរបស់ខ្ញុំ, គំនិតនោះគឺ ធ្វើឃាតប្តីរបស់នាង... ស្ហារឡុតឯង ... ខ្ញុំ !...គឺបញ្ចប់របៀបនេះតែមង្ក...នៅថ្ងៃណាមួយនៅរដូវប្រាំងរដូវ នៅពេលល្ងាចដ៏ល្អមួយ ស្ហារឡុត ឯងកំពុងឡើងទៅលើភ្នំកុំភ្លេចនឹកមកខ្ញុំសោះណា៎ ហើយស្ហារឡុត ឯងនឹកថា ខ្ញុំបានឡើងមកលើភ្នំនេះជាច្រើនដងណាស់ដែរ។ រួចស្ហារឡុតឯងងាកមើលមកផ្នូរ, មើលមកផ្នូររបស់ខ្ញុំដែលមានខ្យល់បក់មករំភើយៗ បណ្តាលឱ្យស្មៅដ៏ខ្ពស់ៗ យោលចុះយោលឡើង ហើយដែលមានពន្លឺព្រះអាទិត្យអស្តង្គតចែងចាំងមកលើ.... ខ្ញុំនៅស្ងប់ស្ងៀម

ល្អណាស់ពីមុនដំបូង, ហើយឥឡូវនេះ, ឥឡូវនេះ ដែលវត្ថុទាំងឡាយដែលនៅជុំវិញខ្ញុំ ចាប់បញ្ចេញនូវភាពរស់រវើកឡើង ខ្ញុំយំដូចកូនក្មេងម្នាក់អញ្ចឹង » ។

នៅម៉ោង ដប់គត់ វែរទែរ ក៏ហៅអ្នកបំរើឱ្យឡើងមក, ដើម្បីស្លៀកពាក់ឱ្យគាត់ ។ នៅពេលដែលកំពុងស្លៀកពាក់ វែរទែរ ក៏បានប្រាប់ទៅអ្នកបំរើ នោះថា គេនឹងធ្វើដំណើរអស់រយៈពេលបីបួនថ្ងៃ ហើយក៏ប្រាប់ឱ្យឈ្នួលបំរើ នោះ រៀបចំបត់សម្លៀកបំពាក់ដាក់ទៅក្នុងហឹប ។ វែរទែរបានឱ្យយកបញ្ជីទិញ របស់របរដែលពុំទាន់បានបង់ថ្លៃមកឱ្យគាត់ ហើយឱ្យទៅយកសៀវភៅដែលគេបានខ្ចីមកវិញ ព្រមទាំងបញ្ជាឱ្យគេផ្តល់ប្រាក់ពីរខែមុនទៅអ្នកក្រដែល ឧស្សាហ៍មកសុំទានខ្លួនរាល់សប្តាហ៍ ។

វែរទែរ បានឱ្យគេយកអាហារពេលល្ងាចមកបរិភោគនៅក្នុងបន្ទប់ លុះបរិភោគរួចហើយ គេក៏បានដើរទៅផ្ទះអ្នក មើលការខុសត្រូវក្នុងស្រុក ។ ប៉ុន្តែដោយគាត់ពុំនៅ វែរទែរ ក៏ដើរលេងនៅក្នុងសួនយ៉ាងសញ្ជប់សញ្ជឹងៈ គេហាក់បីដូចជាខំប្រមូលផ្តុំនូវអនុស្សាវរីយ៍ដ៏ស្រងូតស្រងាត់ទាំងឡាយ ដែលមាននៅក្នុងខ្លួនគេ ។ ក្មេងៗដែលនៅទីនោះនាំគ្នារត់តាមក្រោយ ហើយស្ទុះមកអោបដៃអោបជើង វែរទែរ ។ ក្មេងទាំងនោះ និយាយប្រាប់ វែរទែរ យ៉ាងសប្បាយថា ស្អែកនេះ, ហើយស្អែកមួយទៀត, ហើយមួយថ្ងៃទៀត ឡូឡុត ( Lolotte ) ( [១] ) នឹងឱ្យអំណោយមកវាក្នុងឱកាសបុណ្យណូអែល, ហើយក្មេងទាំងនោះក៏ នាំគ្នានិយាយចចេកចចាចអំពីថ្ងៃដ៏ធំរបស់វានេះ ដោយបញ្ចេញនូវការស្រមៃទាំងប៉ុន្មានដែលវាមាន ។ វែរទែរ ក៏និយាយជាមួយនឹងក្មេងនោះថា : « ហ្នឹង ហើយ ! ថ្ងៃស្អែក ហើយថ្ងៃស្អែកមួយទៀត ហើយមួយថ្ងៃទៀត ... » ។ វែរទែរ ក៏ចាប់ត្រកងអោបក្មេងទាំងនោះនៅក្នុងសភាពដ៏ទន់ភ្លន់បំផុត ហើយនៅពេលដែល វែរទែរ រៀបនឹងចេញបាត់ទៅស្រាប់តែក្មេងម្នាក់ដែលតូចជាងគេ ឈោងទៅខ្សឹម វែរទែរ ដើម្បីនឹងប្រាប់ថា បងវាបានសរសេរសេចក្តីថ្លែងអំរគុណ និង សេចក្តីសរសើរសម្រាប់ឪពុកវាមួយ អាល់ប៊ែរត៍មួយ ស្ហារឡុត មួយហើយនឹង វែរទែរ មួយទៀតស្រេចអស់ហើយ, វាបានប្រាប់ទៀតថា វានឹងយកសេចក្តីថ្លែងអំរគុណ និងសេចក្តីសរសើរនោះទៅឱ្យតាំងពីព្រលឹមនៅថ្ងៃចូលឆ្នាំ ។ សំដីរបស់ក្មេងចុងក្រោយនេះបានធ្វើឱ្យ វែរទែរ ចែកវត្ថុបន្តិចបន្តួចទៅឱ្យក្មេងទាំងនោះ ហើយគេក៏ឡើងជិះសេះចេញបាត់ទៅបន្ទាប់ពីបានផ្តាំឱ្យយកពរសព្ទសាធុការទៅឱ្យជីតាវាផង ។ វែរទែរ ជិះសេះបណ្តើរសម្រក់ទឹកភ្នែក បណ្តើរ ។

គេបានត្រឡប់មកដល់ផ្ទះនៅពេលម៉ោងប្រាំល្ងាច ហើយបានបញ្ជា ទៅឱ្យអ្នកបំរើស្រី រៀបចំអុជភ្លើង ហើយមើលយ៉ាងណាកុំឱ្យភ្លើងនោះរលត់មុនពេលយប់ជ្រៅ ។ បន្ទាប់មក វែរទែរ ក៏បញ្ជាឱ្យអ្នកបំរើប្រុសរៀបចំដាក់សៀវភៅ និង អាវទៅក្នុងបាតហឹប ព្រមទាំងបត់សម្លៀកបំពាក់ឯទៀតទុកផង ។ រួចគេក៏ឡើងទៅសរសេរវគ្គបញ្ចប់នៃសំបុត្ររបស់គេ ចំពោះ ស្ហារឡុត : « កុំបាច់ចាំខ្ញុំអី ។ ស្ហារឡុត ឯងស្មានតែខ្ញុំនឹងស្តាប់សំដីរបស់ ស្ហារឡុត ឯងមែនទេ គឺស្មានតែខ្ញុំនឹងមកជួប ស្ហារឡុត ឯង នៅពេលមុនបុណ្យណូអែលមែនទេ ។ ស្ហារឡុត ខ្ញុំនឹងមកក្នុងថ្ងៃនេះ ហើយឥតចាំពេលណាទៀតឡើយ ។ នៅថ្ងៃមុនពេលបុណ្យណូអែល ស្ហារឡុត នឹងឡើងញ័រចំប្រប់ ហើយនឹងបញ្ចេញទឹកនេត្រាទាល់តែជោគសំបុត្រនេះអស់ ។ ខ្ញុំចង់បានអញ្ចឹងណាំ ហើយរឿងហ្នឹងវាត្រូវតែអញ្ចឹង ! ឱ ស្ហារឡុត អើយ ខ្ញុំសប្បាយចិត្តណាស់ ដោយបានសម្រេចចិត្តដូច្នេះ ! » ។

ពោលពីនាង ស្ហារឡុត វិញមង្ក ។ បន្ទាប់ពីការសន្ទនាចុងក្រោយបង្អស់ជាមួយ វែរទែរ នាង ស្ហារឡុត ស្ថិតនៅក្នុងស្ថានភាពមួយយ៉ាងចម្លែក ។ នាងហាក់បីដូចជាដឹងថា នាងពិបាករស់នៅណាស់ដោយឥត វែរទែរ ។ នាង ហាក់បីដូចជាដឹងថា វែរទែរ ច្បាស់ជាពុំអាចរស់នៅដោយឥតនាងបានឡើយ ។ នាងនៅតែម្នាក់ឯង ហើយគ្មានបងប្អូនប្រុសស្រីណាម្នាក់នៅជិតឡើយ ។ ណាង បណ្តែតអារម្មណ៍យ៉ាងស្ងប់ស្ងៀមទៅលើស្ថានភាពរបស់នាង : នាងនឹកឃើញថា ពីថ្ងៃនេះតទៅជីវិតរបស់នាងត្រូវនៅចងភ្ជាប់ជាមួយនឹងជីវិតរបស់បុរសម្នាក់ ដែលនាងស្គាល់យ៉ាងច្បាស់នូវតម្លៃស្នេហា និងស្វាមីភក្តិចំពោះនាង ហើយដែលនាងស្រឡាញ់វិញយ៉ាងខ្លាំងណាស់ដែរ, បុរសនោះគឺ អាល់ប៊ែរត៍ ប្តីរបស់នាងដែលមានចរិតស្ងប់ស្ងៀមហើយរឹងប៉ឹងមាំមួនផង ដែលព្រះលោកបាន បញ្ជូនមកឱ្យនាងដើម្បី រៀបចំសុភមង្គលឱ្យកូនរបស់នាង ។ ប៉ុន្តែនៅ

ពេលជាមួយគ្នានោះ នាងក៏ជាប់ចិត្តនឹង វែរទែរ ណាស់ដែរ។ ចំពោះនាង វែរទែរ នេះ នាងស្រឡាញ់រាប់អានណាស់ដែរ។ អនុស្សាវរីយ៍ទាំងឡាយបានចងភ្ជាប់នាង ជាមួយនឹង វែរទែរ ក្រៃលែងរហូតដល់ថ្នាក់ដែលនាងពុំអាចបំភ្លេចបានទាល់តែសោះ ។ នាងធ្លាប់ប្រស្រ័យទាក់ទងផ្លូវមនោសញ្ចេតនាជាមួយនិងបុរសនេះយ៉ាងជិតស្និទ្ធិ ហើយនាងដឹងថា បើបាត់ វែរទែរ ទៅនាងច្បាស់ជានៅ ហោលហាលជាពុំខាន គឺការហោលហាលមួយដែលគ្មានអ្វីមកបំពេញបាន។ នាងចេះតែនឹកថាប្រសិនបើនាងអាចធ្វើ វែរទែរ ទៅជាប្អូនបាន, ប្រសិនបើនាងអាចរៀបការ វែរទែរ ទៅឱ្យមិត្តរបស់នាងណាម្នាក់បាន នាងពុំដឹងជាសប្បាយយ៉ាងណាទេ ! នាងខំស្រាវជ្រាវក្នុងគំនិតរកមិត្ររបស់នាងណាម្នាក់ដែលអាចធ្វើជាប្រពន្ធ វែរទែរ បាន ប៉ុន្តែនាងរកពុំឃើញទាល់តែសោះ ពីព្រោះនាងចេះតែ ឃើញគុណវិបត្តិរបស់មិត្រនាងទាំងនោះជានិច្ច។ គឺនៅក្នុងការបណ្ដែតអារម្មណ៍របស់នាងនេះហើយ ដែលនាងបានដឹងយ៉ាងច្បាស់ថា បេះដូងរបស់នាងមានចំណុចខ្មៅខ្លះ ដែលធ្វើឱ្យនាងអៀន ហើយខំលាក់យ៉ាងខ្ជាប់ខ្ជួនជាទីបំផុត។ ប៉ុន្តែនៅពេលដដែលនោះ មានកូនចិត្តមួយទៀត ចេះតែជម្រុញចិត្តនាងកុំឱ្យលាក់នូវចិត្តសំងាត់នេះ។ ចិត្តរបស់នាងបរិសុទ្ធសោះល្អសោះកាលពីមុន ប៉ុន្តែ ឥឡូវនេះហាក់ដូចជាមាន ស្បៃនៃការក្រៀមក្រំដ៏ធំធេងមួយមកគ្របដណ្តប់នាង ហើយធ្វើឱ្យនាងមើលសុភមង្គលរបស់នាងយ៉ាងស្រវាំងភ្នែក។

នៅម៉ោងប្រាំមួយកន្លះ នាង ស្ហារឡុត ឮសូរស្នូរជើង វែរទែរ ដែលកំពុងឡើងជណ្តើរមក។ ស្នូរជើងនេះ នាងស្ហារឡុតស្គាល់យ៉ាងច្បាស់ហើយ បន្ទាប់មកទៀត នាងឮសូរសម្លេង វែរទែរ សួររកនាង។ បេះដូងនាងឡើងញ័រចំប្រប់នៅពេលដែល វែរទែរ ដើរជិតមកដល់នាង។ គឺជាលើកដំបូងហើយ ដែលនាងញ័ររបៀបនេះ។ តាំងពីនាងស្គាល់ វែរទែរ មកនាងពុំដែលមានការ រំភើបញាប់ញ័រចម្លែកដូចពេលនេះឡើយ។ នាងសឹងតែប្រាប់គេឱ្យទៅប្រាប់ វែរទែរ ថានាងឥតនៅផ្ទះទេ។ នៅពេលដែល វែរទែរ ដើរចូលមកស្រាប់តែ នាងភ្លាត់សម្លេងនិយាយក្នុងការវិលវល់ថា : « ម៉េចក៏ វែរទែរ ឯងមិនកាន់ពាក្យសច្ចៈដូច្នេះ ! »- វែរទែរ ឆ្លើយថា : « ខ្ញុំឥតទាន់បានសន្យាអីឯណា »។ នាង ស្ហារឡុត បន្តទៅទៀតថា : « យ៉ាងហោចណាស់ក៏ វែរទែរ គួរអាណិតដល់ការអង្វរកររបស់ខ្ញុំដែរ ខ្ញុំអង្វរដូច្នេះ គឺដើម្បីឱ្យយើងបានសុខទាំងអស់គ្នាតែប៉ុណ្ណោះ » ។

នៅពេលដែលនាង ស្ហារឡុត និយាយជាមួយ វែរទែរ នាងស្ថិតនៅក្នុងការវិលវល់មួយដ៏ធំធេងហើយ នាងហាក់ដូចជាពុំដឹងថា នាងបាននិយាយអ្វីខ្លះទៅ វែរទែរ ផង។ នៅក្នុងការវិលវល់ដដែលនោះ នាងបានប្រាប់គេឱ្យទៅ ហៅមិត្តស្រី១ខ្លះរបស់នាងឱ្យមកលេង ដើម្បីចៀសវាងកុំឱ្យនៅតែពីរនាក់ វែរទែរ។ វែរទែរ យកសៀវភៅមកសងវិញ ហើយក៏ទារខ្ចីសៀវភៅខ្លះទៀត ។ នាង ស្ហារឡុត បន់ឱ្យតែមិត្តស្រី១របស់នាងឆាប់មកដល់។ ប៉ុន្តែមានកូនចិត្តមួយចង់មិនឱ្យមកទេវិញ។ កំពុងតែគិតដូច្នេះ ស្រាប់តែស្រីបំរើនាងចូលមកដល់ហើយប្រាប់នាងថាមិត្តស្រី១របស់នាងសុំអភ័យទោសដោយមិនបានមកព្រោះជាប់រវល់ ។

មុនដំបូង នាង ស្ហារឡុត ចង់ឃាត់ឱ្យអ្នកបំរើនេះនៅធ្វើការក្នុងបន្ទប់ជិត ប៉ុន្តែបន្ទាប់មកនាងក៏ប្តូរគំនិតទៅវិញ។ វែរទែរ ដើរចុះដើរឡើងពេញក្នុងបន្ទប់។ នាងក៏ទៅអង្គុយនៅតុគ្រឿងភ្លេងរនាត ហើយក៏ចាប់ផ្តើមលេងភ្លេងមួយបទតូច ប៉ុន្តែដោយដៃនាងឡើងរឹង នាងក៏លេងទៅទៀតមិនកើត ហើយក៏ក្រោកដើរចេញមកអង្គុយជាមួយ វែរទែរ នៅកៅអីពូកវែង។ នាងសួរ វែរទែរ ថា : « អស់សៀវភៅមើលហើយឬ ? នុ៎ះ នៅក្នុងថតតុខ្ញុំមានសៀវភៅចម្រៀងរបស់ អូស៊ីយ៉ង់ដឺ ( Ossiand ) ដែល វែរទែរ ឯងបានបកប្រែ : ខ្ញុំពុំទាន់បានអានផង ពីព្រោះខ្ញុំសង្ឃឹមថា វែរទែរ ឯងនឹងអានឱ្យខ្ញុំស្តាប់ហើយ ខ្ញុំចេះតែចាំរហូតមក »។ វែរទែរ ញញឹមហើយដើរទៅយកសៀវភៅនោះ។ នៅពេលដែល វែរទែរ កាន់សៀវភៅភ្លាម ស្រាប់តែខ្លួនគេទាំងមូលឡើងព្រឺព្រួចអស់ ហើយទឹកភ្នែកក៏ហូរមកនៅពេលដែលគេបើកសៀវភៅឡើង, វែរទែរ ក៏អង្គុយចុះហើយចាប់ផ្តើមអាន។

លុះអានចប់ហើយ ទឹកភ្នែករបស់ ស្ហារឡុត ក៏បានហូរពេញមកលើ ថ្ពាល់របស់នាង។ ទឹកភ្នែកនេះធ្វើឱ្យបេះដូងនាងបានធូរស្រាល។ តាមការពិត វែរទែរ អាចពុំទាន់ចប់ផងទេ ប៉ុន្តែដោយឃើញនាងយំដូច្នោះ គេក៏បញ្ចប់តែមង្គទៅ ហើយគ្រវែងសៀវភៅនោះចោល។ វែរទែរ

ចាប់ដៃនាងថ្នមៗ ហើយក៏បង្ហូរទឹកភ្នែកខ្លួននៅពេលជាមួយគ្នានោះ គឺទឹកភ្នែកដ៏ល្វីងជូចត់។ នាង ស្ការឡេត ដៃម្ខាងទប់ខ្លួននាង ដៃម្ខាងទៀតកាន់កន្សែងខ្ទប់មុខ។ ការរំជើប រំជួលនៃគូស្នេហ៍ទាំងពីរនេះមានកំរិតខ្លាំងឥតឧបមា ៖ គេនឹកសង្វេគទៅដល់ ព្រហ្មលិខិតដ៏អាក្រក់របស់គេ។ បបូមាត់នឹងភ្នែករបស់ វ៉េរទែរ ទៅផ្តិតជាប់នឹងដៃនាង ស្ការឡេត។ បបូមាត់ និងភ្នែកនេះ ដែលផ្តិតនៅជាប់នឹងដៃនាងធ្វើឱ្យនាងក្តៅ រលាកយ៉ាងខ្លោចផ្សា។ ខ្លួននាងឡើងញ័រ ហើយចង់គេចឱ្យផុតពី វ៉េរទែរ តែម្តង។ ប៉ុន្តែដោយក្តីឈឺចាប់និងក្តីអាណិតខ្លាំងពេក នាងក៏អស់សេចក្តីក្លាហានរលីង ហើយសុខចិត្តនៅឱ្យ វ៉េរទែរ ថើបដៃរបស់នាង។ នាងរកម្លាំងក្រោកពុំរួចទាល់តែសោះ ហើយហាក់បីដូចជាមានដុំសំណមួយផ្ទាំងធំសង្កត់នាងជាប់។ នាងដកដង្ហើមធំមួយចោល ហើយបន្តការយំសោកសង្រេងរបស់នាងតទៅទៀត។ នាងអង្វរឱ្យ វ៉េរទែរ អានតទៅទៀត។ សម្លេងនាងពិរោះដូចសម្លេងទេពធីតា។ វ៉េរទែរ ឡើងញ័រពេញសព៌ាង្គកាយ ហើយបេះដូងរបស់គេ ស្ទើរបែកជាពីរ, គេដើរទៅយកសៀវភៅនោះមកវិញ ហើយក៏ចាប់អានតទៅទៀតទាំងរអាក់រអួល។

នៅម៉ោង ដប់មួយ វ៉េរទែរ បានសួរទៅមនុស្សបំរើរបស់ខ្លួនថា តើអាល់ប៊ែរត៍ត្រឡប់មកផ្ទះវិញហើយឬនៅ។ ឈ្នួលបំរើនោះក៏ឆ្លើយប្រាប់មកវិញថា ឃើញអាល់ប៊ែរត៍ដឹកសេះត្រឡប់មកវិញហើយ។ វ៉េរទែរ ក៏ឱ្យមនុស្ស បំរើនោះយកសំបុត្រមួយទៅឱ្យអាល់ប៊ែរត៍។ សំបុត្រនោះឥតមានបោះត្រាទេ ហើយមានសេចក្តីដូចតទៅ ៖

« សូមមេត្តាឱ្យខ្ញុំខ្ចីកាំភ្លើងខ្លីរបស់អ្នកឯង ត្បិតខ្ញុំត្រូវធ្វើដំណើរមួយ ដែលខ្ញុំចង់ធ្វើ។ លាហើយ។ សូមនៅឱ្យបានសុខសប្បាយ » ។

នាង ស្ការឡេត និន្ទ្រាឥតលក់អស់ពេញមួយយប់ បន្ទាប់ពីនាងបានជួប វ៉េរទែរ នៅពេលចុងក្រោយបង្អស់។ សេចក្តីបារម្ភរបស់នាងបានក្លាយទៅជាការពិតទាំងអស់។ ឈាមដ៏ថ្លារបស់នាងបានត្រឡប់ទៅជាល្អក់អស់ ។ មនោសញ្ចេតនាទាំងឡាយរបស់នាង ក៏ពុះកញ្ជ្រោលពេញទាំងបេះដូងដ៏ថ្លៃថ្នូររបស់នាង។ តើកំដៅដែលធ្វើឱ្យមនោសញ្ចេតនារបស់នាងបានពុះកញ្ជ្រោល ពេញទាំងដើមទ្រូងរបស់នាងនេះមកពីវ៉េរទែរឬ ? ឬមួយក៏មកពីឥរិយាបថ ដ៏ក្លាហានហួសហេតុ ហើយដែលផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់នាង ? ឬមួយក៏មកពីការប្រែប្រួលពីភាពបរិសុទ្ធ ភាពស្ងប់ និង សេចក្តីទុកចិត្តចំពោះខ្លួនឯងមកដល់ស្ថានភាពថ្មីនេះ ? តើនាងមើលមុខប្តីរបស់នាងយ៉ាងណាទៅវិញទៅ ? តើនាងប្រាប់រឿងនាងជាមួយ វ៉េរទែរ របៀបណាទៅ ? នាងអាចប្រាប់ប្តីនាង ទាំងអស់បាន ប៉ុន្តែនាងមានកូនចិត្តមួយជម្រុញឱ្យនាងលាក់ទៅវិញហើយ មិនមែនលាក់ត្រឹមតែចំពោះប្តីនាងទេ គឺនាងលាក់ទាំងខ្លួនឯងទៅទៀត គឺនាងពុំព្រមទទួលស្គាល់នូវមនោសញ្ចេតនាខ្លួនឯង។ នាងភ័យខ្លាចតែប្តីនាងដឹងអំពីការស្និទ្ធស្នាលចុងក្រោយបង្អស់របស់នាងជាមួយនឹង វ៉េរទែរ ពីព្រោះនាងពុំអាចដឹងប្រតិកម្មរបស់ប្តីនាងបានឡើយ។ ប្តីនាងជាមនុស្សម្នាក់ ដែលនាងពុំដែលលាក់រឿងអ្វីឡើយរហូតមកដល់ពេលនេះ។ គឺនៅក្នុងការជ្រួលច្របល់នៃមនោសញ្ចេតនានេះហើយ ដែលធ្វើឱ្យនាងអៀនខ្មាសជាអនេក។ គំនិតរបស់នាងបាញ់ឆ្ពោះតែទៅរក វ៉េរទែរ ដែលនាងយល់ឃើញថា ជាមនុស្សអស់សង្ឃឹមចាំតែថ្ងៃស្លាប់ ហើយដែលនាងពុំអាចបោះបង់ចោលបាន ប៉ុន្តែដែលនាងត្រូវតែ បណ្តោយទៅតាមព្រហ្មលិខិតរបស់គេ។ នាងដឹងយ៉ាងច្បាស់ថា បើបាត់នាងមួយទៅ វ៉េរទែរនឹងក្លាយខ្លួនទៅជាមនុស្សឥតន័យ។ នាងនឹកឃើញថា ម្នាក់ៗសំអាងទៅលើសិទ្ធិរបស់ខ្លួន គឺសិទ្ធិនៃការស្រឡាញ់ ហើយម្នាក់ៗក៏នឹកទៅដល់ព្រេងវាសនារបស់ម្នាក់ទៀត។ ប៉ុន្តែម្នាក់ៗសុទ្ធតែដាក់កំហុសទៅម្នាក់ទៀតជាដរាប។ នាងចេះតែនឹកថា ប្រសិនបើអ្នកទាំងពីរនេះអាចយោគយល់គ្នាទៅ វិញទៅមកបាន នាងពុំដឹងជាសប្បាយយ៉ាងណាទេ ហើយ វ៉េរទែរ ក៏អាចរកច្រកចេញបានដែរ។

បន្តិចក្រោយមក អាល់ប៊ែរត៍ក៏មកដល់។ នាង ស្ការឡេត ក៏ស្ទុះទៅទទួល ប៉ុន្តែមុខនាងឡើងអៀនហាក់ដូចជាមានអ្វីមួយជាសម្ងាត់នៅក្នុងចិត្តនាង។ អាល់ប៊ែរត៍ មានទឹកមុខមិនសូវសប្បាយទេ ពីព្រោះពុំទាន់បានបង្ហើយ កិច្ចការរបស់ខ្លួនឱ្យអស់នៅឡើយ។ អាល់ប៊ែរត៍ ក៏សួរទៅ ស្ការឡេតថា តើមាន រឿងអ្វីប្លែកទេ។ នាង ស្ការឡេត ក៏ឆ្លើយយ៉ាងប្រញាប់ទៅវិញថា វ៉េរទែរ បានមកលេងផ្ទះពីពេលល្ងាច។ រួចអាល់ប៊ែរត៍ ក៏សួរទៅទៀតថា តើមានអ្នកណាផ្ញើសំបុត្រមកទេ។ នាង ស្ការឡេត ប្រាប់ទៅវិញថា មានសំបុត្រមួយ ហើយនិងកញ្ចប់ខ្លះដែលនាងបានយកទៅដាក់ក្នុងបន្ទប់ស្រេចរួចទៅហើយ។ វត្តមានរបស់ប្តីនាងបានធ្វើឱ្យនាងបាត់រំភើបញាប់ញ័រ ដូចជាមានកំដៅអ្វីមួយដែលធ្វើឱ្យនាងកក់ក្តៅ ហើយស្ងប់ស្ងៀម, កំដៅនោះគឺ អនុស្សាវរីយ៍នៃសប្បុរសធម៌, នៃសេចក្តីស្នេហា,នៃការចិត្តល្អរបស់ប្តីនាង។ នាងខិត

ខំលាក់កូនចិត្តរបស់នាង ដើម្បីកុំឱ្យប្ដីនាង ពិបាកចិត្ត ប៉ុន្តែស្រាប់តែនាងក្រឡេកទៅឃើញអ្នកបំរើរបស់ វែរទែរ មកដល់។ អ្នកបំរើនោះហុចសំបុត្រមួយទៅអាល់ប៊ែរត៍។ លុះអានចប់ហើយ អាល់ប៊ែរត៍ ក៏ងាកមកនិយាយជាមួយប្រពន្ធថា : « ឱ្យកាំភ្លើងខ្លីយើងទៅគាត់ទៅ។ សូមឱ្យគាត់ធ្វើដំណើរឱ្យបានសុខសប្បាយ » ។ ឃ្លាចុងក្រោយ នេះ អាល់ប៊ែរត៍ និយាយទៅអ្នកបំរើរបស់ វែរទែរ ។ ចំណែកនាង ស្ហារឡុត វិញ កាលបើដឹងថាស្ថានការណ៍មានដំណើរបែបមិនស្រួលដូច្នេះ ឡើងទន់ជង្គង់ ហាក់ដូចជាត្រូវរន្ទះបាញ់។ នាងខំងើបឈរឱ្យបានស្រួលឡើងវិញ ប៉ុន្តែដោយជើងនាងញ័រខ្លាំងពេកនាង ក៏ដើរឆ្ពោះទៅជញ្ជាំង ដែលមានព្យួរកាំភ្លើងនោះតែម្ដងទៅ។ លុះដោះកាំភ្លើងពីជញ្ជាំងបានហើយ នាង ស្ហារឡុត ក៏យកមក ជូតធូលីចេញ ហើយរកកម្លាំងនឹងហុចកាំភ្លើងនោះទៅ អាល់ប៊ែរត៍ សឹងតែពុំបានទាល់តែ អាល់ប៊ែរត៍សម្លក់នាងយ៉ាងខ្លាំងទើបនាងប្រថុយហុចទៅ ។ បេះដូងនាងឡើងញ័រចំប្រប់ ពីព្រោះនាងទើបតែនឹងបាននិយាយអ្វីក៏ពុំរួចហើយ ក៏ដើរចូលទៅសម្ងំនៅក្នុងបន្ទប់ដើម្បីថ្លឹងមើលស្ថានការណ៍។ នាងសង្ស័យយ៉ាងខ្លាំងថា ស្ថានការណ៍ពិតជាពុំស្រួលមែនទែនហើយ។ នាងឡើងជ្រួលច្រាលពេញទាំងប្រាណ : បន្តិចនាងចង់ប្រាប់ហេតុការណ៍ទៅប្ដីនាងទាំងអស់បន្តិចនាងក៏ចង់លាក់ទៅវិញ ដោយគិតថា ទោះបើប្រាប់ទៅក៏ឥតប្រយោជន៍ដែរ ពីព្រោះស្ថានការណ៍នេះវាគ្មានច្រកស្រេចទៅហើយ។ នាងចង់អង្វរប្ដីនាងឱ្យទៅផ្ទះ វែរទែរ ប៉ុន្តែឱកាសពុំហុចឱ្យទាល់តែសោះ ណាមួយគេទើបនឹងរៀបចំបរិភោគអាហារណាមួយមិត្តស្រីរបស់នាងម្នាក់ក៏មកដល់ ហើយក៏បរិភោគអាហារជាមួយទៀត។ ដោយមិត្តស្រីនាងនោះនិយាយពុំចេះចប់ការជជែកគ្នាក៏ចេះតែបន្តរហូតទៅ : រហូតទៅ...........

នៅពេលដែលអ្នកបំរើរបស់ វែរទែរ បានប្រគល់កាំភ្លើងទៅឱ្យម្ចាស់ខ្លួន ហើយចិត្តរបស់ វែរទែរ ក៏ឡើងរំភើបញាប់ញ័រពោរពេញទៅដោយមន្តស្នេហ៍ ជាពិសេសកាលបើគេដឹងថាគឺ ស្ហារឡុត តែម្ដងដែលជាអ្នកប្រគល់កាំភ្លើងមក។ វែរទែរ ឱ្យអ្នកបំរើយកនំប៉័ង និងស្រាទំពាំងបាយជូមកឱ្យខ្លួនរួចក៏អនុញ្ញាតឱ្យអ្នកបំរើនោះទៅបរិភោគបាយ។ គេក៏ចាប់ផ្ដើមសរសេរសំបុត្របន្តមកទៀត :

« កាំភ្លើងនេះ គឺកាំភ្លើងដែល ស្ហារឡុត ឯងបានប្រគល់មក, គឺជាកាំភ្លើងដែល ស្ហារឡុតឯងបានជូតធូលីចេញយ៉ាងស្អាត, កាំភ្លើងនេះខ្ញុំថើប ហើយថើបទៀត ពីព្រោះជាកាំភ្លើងដែល ស្ហារឡុតឯងបានកាន់ : ឱទេពធីតាបណ្ដូលចិត្តអើយ អ្នកបានបើកផ្លូវឱ្យការសម្រេចចិត្តរបស់ខ្ញុំបានចេញយ៉ាងច្បាស់លាស់ ! ស្ហារឡុត អ្នកប្រគល់កាំភ្លើងនេះមកខ្ញុំ .... ខ្ញុំពេញចិត្តណាស់ ពីព្រោះខ្ញុំឱ្យ សេចក្ដីស្លាប់នេះចេញពីដៃស្ហារឡុតឯងតែម្ដង។ ស្ហារឡុត ដឹងទេ ខ្ញុំបានសួរអ្នកបំរើខ្ញុំខ្ទេចខ្ទីអស់។ ខ្ញុំដឹងថាដៃរបស់ ស្ហារឡុត ឯងឡើងញ័រនៅពេលដែល ស្ហារឡុតឯងប្រគល់កាំភ្លើងមក, ប៉ុន្តែគួរឱ្យស្ដាយដែល ស្ហារឡុត ឯងឥតបាន និយាយលាខ្ញុំមួយម៉ាត់ ! ស្ដាយណាស់ ! ស្ដាយណាស់ ! ឥតមានលាសោះ......! ស្ហារឡុត ឯងបិទបេះដូងទៅវិញទេដឹង .......គឺបិទនៅពេលដែលស្នេហារបស់ខ្ញុំ ចំពោះ ស្ហារឡុត ឯងរៀបចំធ្វើអើយស្នេហានេះពុំងាយនឹងរលាយរលត់ជាដាច់ខាត ហើយរស់រវើកនៅគ្រប់សតវត្សរ៍ ! ខ្ញុំដឹងថា ស្ហារឡុតឯងពុំអាចនឹងស្អប់មនុស្សម្នាក់ដែលបានបូជាជីវិតចំពោះ ស្ហារឡុត ឯងឡើយ » ។

លុះបរិភោគអាហារពេលល្ងាចរួច វែរទែរ ក៏បញ្ជាឱ្យអ្នកបំរើរៀបចំដាក់អីវ៉ាន់ទៅក្នុងហឹបឱ្យហើយ។ គេហែកក្រដាសចោលអស់ច្រើនសន្លឹកហើយ ក៏ដើរចេញទៅក្រៅបាត់ទៅ ដើម្បីយកប្រាក់បំណុលបន្តិចបន្តួចទៅសងគេ។ បន្ទាប់មកគេក៏បានត្រឡប់មកផ្ទះវិញ។ នៅពេលដែលគេរៀបចេញទៅក្រៅម្ដងទៀត ភ្លៀងក៏បានបង្អុរមក។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ វែរទែរ ចេញទៅដែរ។ គេធ្វើដំណើរចេញទៅក្រៅក្រុង ហើយដើរលេងយ៉ាងស្ងៀមស្ងាត់នៅជុំវិញក្រុងនៅពេលដែលស្បែងងឹតកំពុងតែគ្របដណ្ដប់មកបន្តិចម្ដងៗ ។ លុះយប់ងងឹតមកដល់គេក៏បានត្រឡប់ទៅផ្ទះវិញ ហើយក៏យកសំបុត្រមកសរសេរបន្តទៅទៀត :

« វីលហែម គឺជាចុងក្រោយបង្អស់ហើយ ដែលខ្ញុំបានឃើញវាលចំការ រុក្ខជាតិ ហើយនិងមេឃ។ លាហើយ វីលហែម លាហើយម្ដាយជាទីស្រឡាញ់និងដ៏ចិត្តល្អ ! អភ័យទោសឱ្យខ្ញុំផង ! សូម វីលហែម ឯងមេត្តាលួងលោមម្ដាយខ្ញុំផង ! សូមឱ្យព្រះជួយថែរក្សាអ្នកទាំងពីរ ! កិច្ចការរបស់ខ្ញុំបាន រៀបចំស្រេចអស់ហើយ។ លាហើយ ! យើងនឹងជួបគ្នានៅពេលក្រោយ ប៉ុន្តែជួបម្ដងនេះប្រហែល ជាជួបគ្នាក្នុងសុភមង្គលហើយ! » ។

« សេចក្ដីឆ្លើយតបរបស់ខ្ញុំ ជាមិត្តភាពចំពោះ អាល់ប៊ែរត៍ ឯងពិតជាពុំសមគួរសោះតែម្ដង។ ប៉ុន្តែខ្ញុំសង្ឃឹមថា អាល់ប៊ែរត៍ ឯងមុខជាអភ័យទោសឱ្យខ្ញុំជាពុំខាន។ ខ្ញុំបានធ្វើឱ្យបរិយាកាសនៃផ្ទះរបស់ អាល់ប៊ែរត៍ ឯងខូចខ្ទេចខ្ទីអស់, ខ្ញុំបានផ្ដាច់ការទុកចិត្តរវាង អាល់ប៊ែរត៍ នឹងប្រពន្ធរបស់ អាល់ប៊ែរត៍ឯង។ លាហើយ ! ខ្ញុំនឹងបញ្ចប់រឿងនេះដោយខ្លួនឯង។ ខ្ញុំសូមឱ្យមរណភាពរបស់ខ្ញុំ ប្រគល់សុភមង្គលមកអ្នកទាំងពីរវិញ ! អាល់ប៊ែរត៍! អាល់ប៊ែរត៍ សូមអ្នកផ្ដល់ សុភមង្គលទៅទេពអប្សរនេះផង ! ការប្រសិទ្ធិពររបស់ព្រះពឹងផ្អែកទាំងស្រុងទៅលើ អាល់ប៊ែរត៍ឯង ! »។

នៅពេលយប់ វែរទែរ រៀបចំក្រដាសដែលជាឯកសាររបស់គេ ដោយហែកចោលឯកសារជាច្រើនបោះទៅក្នុងភ្លើង។ វែរទែរបោះត្រានៅលើខ្ទង់សំបុត្រដែលគេទុកឱ្យ វីលហែម។ សំបុត្រទាំងនោះធ្វើអត្ថាធិប្បាយយ៉ាងខ្លី១ស្ដី អំពីគោលគំនិតខ្លះ១នៃការពិចារណាផ្សេង១។ នៅម៉ោងដប់យប់ វែរទែរ ឱ្យគេ យកឧសមកដុតកំដៅបន្ថែម ។ បន្ទាប់ពីឱ្យអ្នកបំរើយកស្រាទំពាំងបាយជូមួយ ដបមកឱ្យគេ វែរទែរក៏អនុញ្ញាតឱ្យអ្នកបំរើនោះទៅសម្រាកកម្លាំង ពីព្រោះ បន្ទប់អ្នកបំរើនោះនៅដាច់ពីផ្ទះធំ ដែល វែរទែរ នៅ ។

ម៉ោងដប់មួយ បានកន្លងផុតទៅ

វែរទែរ សរសេរបន្តមកទៀត :

« ខ្ញុំបានដើរទៅជិតបង្អួចហើយ, ស្ហារឡុតអើយ ខ្ញុំបានឃើញផ្កាយ នៅលើមេឃអមតៈពីរបីតាមចន្លោះពពកដែលកំពុងតែរសាត់គឺជាពពកដែល មហាខ្យល់ព្យុះបានរុញច្រានមក។ ស្ហារឡុត ឯងឥតធ្លាក់មកវិញទេ។ អនន្តភាពបានក្ដោប ស្ហារឡុត ឯងរួចស្រេចទៅហើយ គឺក្ដោបជាប់ដូចក្ដោបខ្ញុំដូច្នេះ ។ ខ្ញុំឃើញផ្កាយចន្ទោលរទេះ ដែលជាទីស្រឡាញ់បំផុតរបស់ពិភពតារា។ នៅរាត្រីដែលខ្ញុំចេញពីផ្ទះ ស្ហារឡុតឯងមក ខ្ញុំបានឃើញផ្កាយនោះនៅចំពីមុខខ្ញុំតែម្ដង។ ខ្ញុំខំមើលផ្កាយនោះនៅក្នុងភាពស្រវឹងមួយរកថ្លែងពុំបាន។ ខ្ញុំបានលើកដៃទាំងពីរឆ្ពោះទៅផ្កាយនោះជាច្រើនដង ដើម្បីសូមឱ្យគេធ្វើជាសាក្សីខ្ញុំ (.......) ស្ហារឡុត អ្វី១គ្រប់បែបយ៉ាងតែងតែធ្វើឱ្យខ្ញុំនឹកទៅដល់ ស្ហារឡុត ឯងជានិច្ច។ ខ្ញុំនៅជាប់នឹង ស្ហារឡុត ឯងជានិច្ច (.............)

«ឱរូបរាងដ៏សង្ហារជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំសូមផ្ដល់សម្ផស្សនៃរូបរាងនេះទៅ ស្ហារឡុត ឯងចុះហើយសូមឱ្យ ស្ហារឡុត ឯងទទួលយកកិត្តិយសនេះផង។ រូបភាពដ៏សង្ហារនេះ ខ្ញុំថើបពុំចេះចប់ពុំចេះហើយ, ខ្ញុំគោរពគ្រប់ពេលវេលានៅពេលដែលខ្ញុំចូល និងចេញពីបន្ទប់របស់ខ្ញុំ។

« ខ្ញុំបានធ្វើកូនសំបុត្រមួយទៅឪពុក ស្ហារឡុតឯង ដើម្បីឱ្យគាត់ជួយថែរក្សារូបរាងកាយរបស់ខ្ញុំ។ នៅខាងចុងផ្លូវមានដើម « ទីយ៉េល » ពីរដើម។ នៅត្រង់កន្លែងកៀនផ្ទះ មុំដែលបែរមុខទៅរកវាលស្រែ : គឺនៅកន្លែងនោះ ហើយដែលខ្ញុំចង់សម្ងំយ៉ាងសុខសាន្ត។ គាត់មុខជានឹងជួយជ្រោមជ្រែងជាពុំខាន ហើយគាត់មុខតែបំពេញករណីយកិច្ចនេះ ចំពោះមិត្ររបស់គាត់ម្នាក់។ ស្ហារឡុត ឯងជួយអង្វរគាត់ផង (.....) ខ្ញុំចង់ឱ្យគេបញ្ចុះសពខ្ញុំនៅជិតផ្លូវមួយ ឬជិតចន្លោះភ្នំមួយដែលស្ងាត់ជ្រងំជាទីបំផុត, ខ្ញុំចង់ឱ្យបព្វជិតដែលដើរមកជិតនោះធ្វើគារវកិច្ច ហើយបង្ហូរទឹកភ្នែក !

« (......) ឱ ស្ហារឡុតអើយ សូមផ្ដល់សុភមង្គលមួយមកឱ្យខ្ញុំផង គឺសុភមង្គលនៃការស្លាប់ ដើម្បីស្ហារឡុតឯង និងសុភមង្គលនៃការស្មោះត្រង់នឹង ស្ហារឡុត ឯង ! ខ្ញុំនឹងស្លាប់ក្នុងសេចក្ដីក្លាហាន ខ្ញុំនឹងស្លាប់យ៉ាងសប្បាយ ប្រសិនបើខ្ញុំអាចផ្ដល់សេចក្ដីសុខសាន្តទៅ ស្ហារឡុតឯង, ប្រសិនបើខ្ញុំអាចផ្ដល់ឱជារសទៅក្នុងជីវិតរបស់ ស្ហារឡុតឯង។ ប៉ុន្តែគួរឱ្យស្ដាយណាស់ ! សិទ្ធិនេះគឺសម្រាប់ តែមនុស្សពិសេសពីរបីនាក់ប៉ុណ្ណោះ គឺសិទ្ធិនៃការបង្ហូរឈាមចំពោះមិត្តរបស់គេ គឺសិទ្ធិនៃការប្ដូរជីវិតទៅឱ្យមនុស្សដែលគេស្រឡាញ់ ដើម្បីឈោងចាប់យកជីវិតថ្មីមួយទៀត ហើយដែលមានកិរិតលើសជីវិតដើមមួយរយដង។

« ខ្ញុំចង់ឱ្យគេបញ្ចុះសពខ្ញុំទាំងខោអាវរបស់ខ្ញុំនេះ ពីព្រោះជាសម្លៀកបំពាក់ដែល ស្ហារឡុត ឯងបានពាល់ ហើយដែលបានធ្វើឱ្យទៅជាវត្ថុសក្ការៈ ខ្ញុំបានសុំឯកសិទ្ធិពីឪពុករបស់ ស្ហារឡុត ឯងរួចទៅហើយដែរ។ ព្រលឹងរបស់ខ្ញុំនៅឃ្លាំងមើលម្ឈូសរបស់ខ្ញុំជានិច្ច។ សូមកុំឱ្យគេឆែក

ហោប៉ៅខ្ញុំឱ្យសោះ។ បូពណិ ស៊ីជំពូដែល ស្ហារឡុត ឯងពាក់នៅត្រង់សុដន កាលដែលខ្ញុំឃើញ ស្ហារឡុត ឯងជាលើកដំបូងបង្អស់នៅជាមួយកូនរបស់ ស្ហារឡុត ឯង ( អូ ! សូមកុំភ្លេចថើបកូន ស្ហារឡុត ឯងជំនួសខ្ញុំផង ហើយកុំភ្លេចនិទានរឿងមិត្តដ៏កំសត់របស់គេប្រាប់ដល់គេផងក្មេងដ៏ជាទីស្រឡាញ់នេះ ខ្ញុំនៅឃើញច្បាស់នឹងភ្នែកនៅឡើយ កាលគេស្ទុះមករោមខ្ញុំ : ខ្ញុំពុំអាចចោល ស្ហារឡុត ឯងបានទេ គឺតាំងពីដំបូងមកម្ល៉េះខ្ញុំដឹងថា ខ្ញុំពុំអាចចោល ស្ហារឡុត ឯងបានជាដាច់ខាត )....បូនេះខ្ញុំនឹងយកទៅជាមួយខ្ញុំ ! បូនេះ ស្ហារឡុត ឯងបានឱ្យជារង្វាន់មកខ្ញុំនៅថ្ងៃនៃបុណ្យខួបរបស់ខ្ញុំ ! ខ្ញុំនឹងលេបរបស់ទាំងនេះយ៉ាងឆ្ងាញ់ជាទីបំផុត ..... ស្ដាយណាស់ ! ខ្ញុំ ពុំបានដឹងជាមុនសោះថា ដំណើរជីវិតរបស់ខ្ញុំត្រូវមកធ្លាក់កន្លែងហ្នឹង ! ....... សូមនៅឱ្យស្ងប់ស្ងៀមចុះ សូមនៅឱ្យស្ងប់ស្ងៀមចុះ។

« កាំភ្លើងនេះមានគ្រាប់ត្រឹមត្រូវហើយ ................អធ្រាតមកដល់ ហើយ សាធុអញ្ជឹងទៅចុះ ! ស្ហារឡុត ! ស្ហារឡុត ! លាហើយ ! លាហើយ ! » ..........................................................................

អ្នកជិតខាងម្នាក់បានឮស្នូរកាំភ្លើង, ប៉ុន្តែដោយគ្មានឮអ្នកណាគេ ក្រោកឈ្ងូរឆភ្ញាក់ផ្អើលអ្វី អ្នកជិតខាងនោះក៏ឥតអើពើអ្វីដែរ។

ព្រឹកឡើងនៅម៉ោងប្រាំមួយអ្នកបំរើរបស់ វែរតែរ បានចូលទៅក្នុង បន្ទប់ចៅហ្វាយរបស់ខ្លួន ដោយកាន់ចង្កៀងមួយចូលទៅផង។ មនុស្សបំរើនោះបានឃើញ វែរតែរ ដេកដួលស្តូកស្តឹងលើឥដ្ឋ ព្រមទាំងឃើញកាំភ្លើងខ្លីមួយ ហើយនិងឈាមនៅក្នុងបន្ទប់នោះ, គាត់ក៏អង្រ្រន់ហៅប៉ុន្តែគ្មានចម្លើយអ្វីបន្តិចសោះ។ វែរតែរ នៅដង្ហក់ខ្យល់នៅឡើយ។ មនុស្សបំរើក៏រត់ទៅហៅគ្រូពេទ្យរួចក៏ទៅប្រាប់ អាល់ប៊ែរត៍។ និយាយពី ស្ហារឡុតវិញ កាលបើឮសូរគេចុច កណ្តឹងហៅដូច្នេះ ក៏ឡើងញាក់ទទ្រើកដូចកូនសត្វ,អវៈយវៈទាំងឡាយរបស់ នាងញ័រចំប្រប់, នាងដាស់ប្តីរបស់នាង។ អ្នកទាំងពីរនាក់ក៏ងើបឈរឡើងហើយ អ្នកបំរើ វែរតែរ យំអណ្តើតអណ្តក់ផង ប្រាប់ដំណឹងដ៏អាក្រក់នោះផង។ ស្ហារឡុត ក៏សន្លប់បាត់ស្មារតីនៅជិតប្តីរបស់ខ្លួនទៅ។

លុះគ្រូពេទ្យមកដល់ បុរសដ៏កំសត់ នៅដេកសន្ធឹងលើឥដ្ឋនៅឡើយ គឺនៅក្នុងស្ថានភាពមួយដ៏អស់សង្ឃឹម, ជីពចរនៅដើរនៅឡើយ ប៉ុន្តែអវៈយវៈកម្រើកលែងរួចទាំងអស់។ វែរតែរ បានបាញ់សម្លាប់ខ្លួនឯងមួយគ្រាប់ត្រង់ក្បាលនៅពីលើភ្នែកស្តាំ, ខួរក្បាលបែកខ្ទេចខ្ទីអស់។ ប៉ុន្តែ វែរតែរ នៅដកដង្ហើមនៅឡើយ។ បើតាមមើលឃើញឈាមនៅលើកៅអី គេអាចសន្និដ្ឋានបានថា វែរតែរ បានសម្លាប់ខ្លួនដោយអង្គុយនៅមុខតុសរសេរតូចមួយរបស់ខ្លួន, រួចមកទើបគេដួលទៅលើឥដ្ឋ ហើយនៅពេលដែល វែរតែរ កំពុងប្រកាច់ គេបានននាលខ្លួនគេ នៅជុំវិញកៅអី ។ រួចមកគេក៏ដួលសន្ធឹងនៅជិតបង្អួច ដោយផ្តេកខ្លួនទៅលើឥដ្ឋ ហើយធ្វើចលនាអ្វីទៀតលែងកើត។ គេស្លៀកពាក់ខោអាវឥតមានខ្វះអ្វីឡើយ សូម្បីតែស្បែកជើងកវែងក៏ពុំដោះចេញដែរ។ សម្លៀកបំពាក់ពណ៌ខៀវ ហើយអាវរងាខាងក្រៅពណ៌លឿង។ ពេញមួយផ្ទះរបស់ វែរតែរ នឹងផ្ទះជិតខាង ហើយបន្ទាប់មកមួយក្រុងក៏ភ្ញាក់ផ្អើលយ៉ាងខ្លាំង។

មុននឹងស្លាប់ វែរតែរ ផឹកស្រាទំពាំងបាយជូបានតែមួយកែវគត់។ស្រា នោះឈ្មោះ Emilia galotti។ ដបស្រានៅបើកឆ្លុកចោលនៅលើតុ នៅឡើយ។

អាល់ប៊ែរត៍ឡើងស្រឡាំងកាំងអស់។ រីឯសេចក្តីអស់សង្ឃឹមរបស់ នាង ស្ហារឡុត ពុំអាចរកពាក្យពិពណ៌នាបានឡើយ។

អ្នកមើលការខុសត្រូវក្នុងស្រុក ដែលជាអ្នកចាស់ទុំ លុះបានដំណឹងនេះហើយ ក៏រត់លឿនស្លេវទៅផ្ទះ វែរតែរ ហើយក៏អោបរឹត វែរតែរ ដែលកំពុងដកចង្កាមាន់ ហើយក៏សម្រក់ទឹកភ្នែកច្រោក១ ។ រីឯកូនច្បងរបស់គាត់ក៏ដាក់ភ្នែកចុះយ៉ាងស្រងូតស្រងាត់ ថើបដៃនិងមាត់របស់វែរតែរមក។ វែរតែរ ស្លាប់នៅពេលថ្ងៃត្រង់។ គេយកសាកសព វែរតែរ ទៅកប់នៅពេលយប់វេលាម៉ោងដប់មួយ។ គឺកប់ត្រង់កន្លែងដែល វែរតែរបានសុំជាមុន។ លោកតាដែលជាអ្នក ត្រួតត្រាក្នុងស្រុក ព្រមទាំងកូនគាត់ទាំងអស់នាំគ្នាជូនដំណើរសាកសព។ រីឯ អាល់ប៊ែរត៍វិញឥតបានមកនឹងគេទេ។ គេនាំគ្នាភិតភ័យអំពីសុខភាពរបស់នាង ស្ហារឡុត ដែលមានភាពមិនស្រួលទាល់តែសោះ។ គេបានជួលកម្មករដើម្បីឱ្យសែងសាកសពរបស់ វែរតែរ។ ឥតមានលោកសង្ឃណាម្នាក់ មកចូលរួមជួយ ពិធីបញ្ចុះសពឡើយ។